**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économicques**

*Royal University of Law and Economics*

## សារណាបញ្ចប់ការសិក្សា

# បុត្តភាព

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ខា ស្រីលីន**

**ក. ជីប ថូ**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាដំបូង នាងខ្ញុំ ខា ស្រីលីន និងនាងខ្ញុំ ជីប ថូ ជានិស្សិតឆ្នាំទី ៤ ថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ៖

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- លោកឪពុក **ឈើយ សុខា** អ្នកម្តាយ **ឆ្នា ឡើ** និងលោកឪពុក **អ៊ុក អឿន** អ្នកម្តាយ **អ៊ុក ឡឿន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលលោកទាំងបួនបានផ្តល់កំណើត ការចិញ្ចឹមបីបាច់មើលថែ និងទូន្មាន ប្រៀនប្រដៅកូន ប្រកបដោយព្រហ្មវិហារធម៌ តាំងពីកូនតូចរហូតធំដឹងក្តី។
- លោកព្រឹទ្ធបុរស **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រចារ្យ **ចាំង ស៊ីណាត** ដែលលោកទាំងពីរ តែងតែអប់រំទូន្មាន ប្រៀនប្រដៅ ណែនាំ ដុសខាត់ បង្ហាត់បង្រៀននូវចំណេះ រួមទាំងជំនាញជាច្រើនដល់រូបយើងខ្ញុំទាំងពីរ ប្រៀបដូចជាកូន ដូចជាប្អូន ប្រកបដោយភាពថ្លៃថ្នូរ និងមធ្យ័ត។
- បងប្អូនប្រុសស្រី មិត្តភក្តិ សិស្សច្បង សិស្សប្អូន ដែលអ្នករាល់គ្នាតែងតែផ្តល់នូវកម្លាំងចិត្ត ចែករំលែកសុខទុក្ខ ការអធ្យាស្រ័យ យោគយល់ ផ្តល់ភាពរីករាយ និងគំនិតល្អៗ នៅក្នុងជីវិតជាអ្នកសិក្សារៀន ដើម្បីខ្លួនឯង គ្រួសារ និងសង្គមជាតិ។
- លោកឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន ណែនាំ ចែករំលែកបទពិសោធន៍ ទាំងផ្នែកទ្រឹស្តី និងការអនុវត្ត ដែលឆ្លុះពីតថភាពនៃសង្គមជាក់ស្តែង។
- សូមគោរពដឹងគុណម្តងទៀត ចំពោះលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានខិតខំជួយណែនាំបង្ហាត់បង្រៀន បកស្រាយពន្យល់ នូវចំណុចខ្វះខាត និង អ្វីដែលជាចំណោទបញ្ហា នៅក្នុងកិច្ចការស្រាវជ្រាវនេះ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមគោរពប្រសិទ្ធិពរសព្វសាធុការ មហាប្រសើរបំផុតគ្រប់ប្រការ ដល់អ្នកមានគុណទាំងអស់ ប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួនខ្លាំងក្លា បញ្ញាញាណវៀងវៃ អាយុយឺនយូរ ដើម្បីរួមចំណែកដឹកនាំកសាង និងអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅរក ការអភិវឌ្ឍន៍ វិបុលភាព ស្ថេរភាព និងភាពសម្បូរសប្បាយជានិរន្តរ

# អារម្ភកថា

បន្ទាប់ពី យើងខ្ញុំទាំងពីរបានឆ្លងកាត់នូវការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ តាំងពីឆ្នាំមូលដ្ឋានរហូតដល់ឆ្នាំទី៤នេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺបានធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងច្រើនអនេក ពីសំណាក់លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំបង្ហាត់បង្រៀននិស្សិតយ៉ាងយកចិត្តទុកដាក់ ហើយក៏ជាសក្ខីភាពនាំឱ្យយើងខ្ញុំទាំងពីរឈានឆ្ពោះមកដល់ការសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ ក្នុងរយៈពេលនៃការសិក្សាកន្លងមកនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើផ្នែកឯកជននៃក្រមរដ្ឋប្បវេណី ជាពិសេសមេរៀនដែលនិយាយអំពីញាតិ ក្រោយពីបានសិក្សាមេរៀននេះចប់ យើងខ្ញុំទាំងពីរក៏សម្រេចចិត្តជ្រើសយកប្រធានបទស្តីពី "បុត្តភាព" នេះមកធ្វើជាការស្រាវជ្រាវសម្រាប់បញ្ចប់ការសិក្សា។ យើងខ្ញុំធ្វើការសហការគ្នា ខិតខំសិក្សាស្រាវជ្រាវ និងធ្វើការចងក្រងនូវសៀវភៅសារណានេះឡើង ក្នុងគោលបំណងរួមចំណែកផ្តល់ជាចំណេះដឹងសម្រាប់ឱ្យនិស្សិតជំនាន់ក្រោយដែលអាចយកធ្វើជាការសិក្សារៀនសូត្រ ស្រាវជ្រាវ និងបង្កើនចំណេះដឹងខ្លួនឯងបន្ថែម។

យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការសរសេរប្រធានបទមួយនេះ ព្រមទាំងទទួលបាននូវបទពិសោធន៍ថ្មីៗ បន្ទាប់ពីបានខិតខំ ប្រឹងប្រែង ស្វះស្វែងរកនូវប្រភពឯកសារនានា ក្រមរដ្ឋប្បវេណីគតិយុត្ត លិខិតបទដ្ឋាននានា រួមទាំងទទួលបានការចង្អុលបង្ហាញពីសាស្ត្រាចារ្យផ្នែកច្បាប់ ដែលទាក់ទិននឹងប្រធានបទនៃកិច្ចការសារណាមួយនេះ។

យើងខ្ញុំទាំងពីរ សូមគោរពថ្លែងអំណរគុណជាអនេកប្បការ ចំពោះទឹកចិត្តដ៏ល្អប្រពៃដែលមិនអាចកាត់ថ្លៃបានរបស់លោកព្រឹទ្ធបុរស **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានខិតខំបង្ហាត់បង្រៀន ពន្យល់បកស្រាយ និងជួយណែនាំក្នុងការចងក្រងសៀវភៅសារណាបញ្ចប់ឆ្នាំសិក្សានេះ ដើម្បីជំរុញដំណើរការស្រាវជ្រាវទៅបានយ៉ាងរលូន និងសម្រេចដោយជោគជ័យ។ ទោះបីក្នុងកាលៈទេសៈដ៏លំបាកយ៉ាងណាក្តី ដែលស្ថិតក្នុងសម័យកាលរីករាលដាលរបស់ "វីរុសកូវីដ១៩" យ៉ាងកាចសាហាវ និងត្រូវមានការរក្សាគម្លាតពីសង្គម ដែលជាឧបសគ្គក្នុងការប្រាស្រ័យទាក់ទងគ្នាផ្ទាល់។ តែទោះជាយ៉ាងណាក្តី ក៏លោក លោកស្រីសាស្ត្រាចារ្យនៅតែឆ្លៀតពេល ដើម្បីផ្តល់ការណែនាំ និងជួយកែសម្រួលដល់កិច្ចការស្រាវជ្រាវរបស់យើងទាំងពីរឱ្យមានភាពល្អប្រសើរ។

# មាតិកា

សេចក្តីផ្តើម......................................................................................................១

## ជំពូកទី១

## ការបង្កើតនូវបុត្តភាព

**ផ្នែកទី១៖ សញ្ញាណទូទៅនៃបុត្តភាព**.....................................................................៥
**កថាខណ្ឌទី១ និយមន័យ**.....................................................................................៥
**កថាខណ្ឌទី២ សំបុត្រកំណើត**..................................................................................៥
១. រយៈពេល និងទីកន្លែងចុះសំបុត្រកំណើត..........................................................................៦
២. ក្នុងករណីទារកកើតនៅបរទេស.......................................................................................៧
៣. ការកំណត់នាមត្រកូលរបស់កូន.......................................................................................៨
**កថាខណ្ឌទី៣ ទំនាក់ទំនងបុត្តភាព**..............................................................................៨
១. កូនបង្កើត..................................................................................................................៩
២. សុំកូន.......................................................................................................................៩
២.១ សុំកូនពេញលេញ.....................................................................................................១០
២.២ សុំកូនធម្មតា..........................................................................................................១១
៣. កូនដែលកើតតាមវិធីវេជ្ជសាស្ត្រ......................................................................................១២
**ផ្នែកទី២៖ ការសម្រេចអំពីបុត្តភាព**..........................................................................១៣
**កថាខណ្ឌទី១ អំពីមាតុភាព**......................................................................................១៤
**កថាខណ្ឌទី២ អំពីបិតុភាព**.......................................................................................១៥
១. ការសន្មតបិតុភាព.......................................................................................................១៥
២. ការបដិសេធបិតុភាព...................................................................................................១៦
២.១ បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវសន្មតថាជាឪពុក..............................................១៦
២.២ បណ្តឹងបដិសេធបិតុភាពពីកូន...................................................................................១៧
២.៣ អានុភាពប្រតិសកម្មនៃបណ្តឹងបដិសេធបិតុភាព..............................................................១៨
៣. អំពីការទទួលស្គាល់.....................................................................................................១៨

ផ្នែកទី៣៖ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព......២០
កថាខណ្ឌទី១ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព......២០
១. បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន......២០
២. បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្ដាយ......២១
កថាខណ្ឌទី២ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព......២១

## ជំពូកទី២

## អានុភាពនៃបុត្តភាព

ផ្នែកទី១៖ អំណាចមេបា......២៣
កថាខណ្ឌទី១ មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់......២៣
១. ករណីឪពុកម្ដាយមិនលែងលះគ្នា......២៤
២. ករណីលែងលះ......២៥
កថាខណ្ឌទី២ ករណីអនីតិសង្វាស......២៦
កថាខណ្ឌទី៣ ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា......២៧
១. ការព្យួរ ឬដកហូត......២៧
២. ការលុបចោលការប្រកាសការព្យួរ ឬដកហូត......២៨
៣. ការលាឈប់ធ្វើជាអ្នកមានអំណាចមេបា......២៩
ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា......២៩
កថាខណ្ឌទី១ សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន......២៩
១. ការចិញ្ចឹមថែរក្សាកូន......២៩
២. ការទាមទារឱ្យប្រគល់កូន......៣០
៣. ការគ្រប់គ្រងទ្រព្យសម្បត្តិកូន......៣១
៤. ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់កូន......៣១
៥. ការដាក់ទណ្ឌកម្មកូន......៣២
កថាខណ្ឌទី២ សិទ្ធិ និងករណីយកិច្ចរបស់អ្នកពុំមានអំណាចមេបា......៣២
ផ្នែកទី៣៖ អាហារកាតព្វកិច្ច......៣៣

**កថាខណ្ឌទី១ អាហារកាតព្វកិច្ច និងអាហារកិច្ច** ............ ៣៤
១. បុគ្គលផ្គត់ផ្គង់អាហារកាតព្វកិច្ច............ ៣៤
២. បុគ្គលដែលទទួលបានអាហារកិច្ច (កូន) ............ ៣៥
៣. ការកំណត់សោហ៊ុយចំណាយ ចំពោះផ្គត់ផ្គង់កូនជាអនីតិជន............ ៣៦
**កថាខណ្ឌទី២ ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច**............ ៣៧
**សេចក្តីសន្និដ្ឋាន**............ ៣៩
**អនុសាសន៍**............ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

សុភមង្គលក្នុងគ្រួសារ គឺកើតចេញពីការមានទំនួលខុសត្រូវរបស់មេគ្រួសារ សមាជិកគ្រួសារ និងគោរពតួនាទីរបស់ខ្លួនទៅតាមទំនៀមទម្លាប់ធម្មជាតិ និងសង្គម។ ទន្ទឹមនឹងនេះសេចក្តីស្រឡាញ់រវាងបុរសនិងនារី គឺជាទំនាក់ទំនងមួយដែលជាថ្នូរអាចឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ បង្កើតបានជាគ្រួសារដែលក្នុងគ្រួសារអាចមានសមាជិកដូចជាឪពុក ម្តាយ និងកូន។ ទន្ទឹមនឹងនេះ គ្រួសារខ្លះក៏មិនបានកើតឡើងដោយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ទេ ទោះបីមាននាមជាគ្រួសារក៏ដោយ តាមសន្ទានុក្រមច្បាប់ថា អនីតិសង្វាស។ អាពាហ៍ពិពាហ៍ បង្កើតឱ្យមានជាគ្រួសារថ្មី ទោះបីជាអ្នកគោរពស្រឡាញ់ឪពុកម្តាយរបស់អ្នកក្តី តែក្រោយពេលអ្នករៀបអាពាហ៍ពិពាហ៍ហើយគូ និងកូនរបស់អ្នកត្រូវជាបុគ្គលសំខាន់បំផុតក្នុងជីវិតអ្នក។

ពាក្យថាគ្រួសារ មានតែប្តីប្រពន្ធ គឺវាពុំមានលក្ខណៈពេញលេញនោះទេ លុះត្រាមានអ្វីមួយមកបំពេញបន្ថែមឱ្យមានភាពគ្រប់គ្រាន់ក្នុងពាក្យថាគ្រួសារ នោះ គឺជាកូន។ កូនគឺជាធាតុផ្សំដ៏សំខាន់នៅក្នុងគ្រួសារដើម្បីឱ្យគ្រួសារមួយទទួលបាននូវសុខដុមរមនា។ កូន គឺជាហេតុដែលផ្សារភ្ជាប់នូវទំនាក់ទំនងប្តីប្រពន្ធឱ្យកាន់តែមានភាពល្អប្រសើរឡើង ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីមានចែងពាក់ព័ន្ធនឹងទំនាក់ទំនងឪពុកម្តាយ និងកូន។

អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ គឺជាមូលដ្ឋានចម្បង ដែលធ្វើឱ្យប្តីនិងប្រពន្ធមានទំនាក់ទំនងគតិយុត្តរវាងគ្នា និងអាចបង្កើតជាក្រុមគ្រួសារជាមួយគ្នាបានតាមក្បួនច្បាប់។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍បានដើរតួជាលក្ខខណ្ឌគ្រឹះនៅក្នុងរឿងក្តីនៃការលែងលះ ដោយហេតុថា នៅពេលដំណើរការដោះស្រាយរឿងក្តីលែងលះតុលាការតែងតែបង្គាប់ឱ្យភាគីផ្តល់នូវសំបុត្រអាពាហ៍ពិពាហ៍ដើម្បីធ្វើការពិនិត្យ។ ក្នុងករណីដែលភាគីមិនបានផ្តល់តាមការបង្គាប់នេះទេ តុលាការនឹងមិនជឿថាមានអង្គហេតុនៃការបង្កើតចំណងគតិយុត្តឡើយ។ ដូច្នោះពាក្យសុំនឹងត្រូវបានច្រានចោលដោយដីកាសម្រេច។ ជាគោលការណ៍ចំណងអាពាហ៍ពិពាហ៍មួយអាចក្លាយជាចំណងតាមផ្លូវច្បាប់ ដាច់ខាតត្រូវបំពេញនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់តាមការកំណត់របស់ច្បាប់។ ការណ៍ដែលលែងលះគ្មានមូលហេតុច្បាស់លាស់ ឬច្បាស់លាស់ក៏ដោយ ក៏វាសុទ្ធសឹងតែជាផលវិបាកដល់ភាគីដែលជាសហព័ទ្ធ និងកូន។

ទំនាក់ទំនងឪពុកម្តាយ និងកូន គឺជាចំណងគតិយុត្តដែលត្រូវមានទំនួលខុសត្រូវទាំងការរស់នៅក្នុងគ្រួសារ និងការរស់នៅក្នុងសង្គម។ នៅក្នុងករណីដែលទទួលខុសត្រូវក្នុងគ្រួសារ គឺបុគ្គលជាម្តាយឪពុក មានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន ដែលទាក់ទងនឹងបុគ្គភាព នាមជាអ្នកមានអំណាចមេបា និងទំនួលខុសត្រូវខាងអាហារកាតព្វកិច្ច។

កាតព្វកិច្ចក្នុងទំនាក់ទំនងឯកជន វាមានប្រភពមកពីការសម្តែងឆន្ទៈរបស់បុគ្គលឯកជនដែលជាខ្លឹមសាររបស់គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ឬគោលការណ៍ស្វ័យភាពនៃឆន្ទៈ។ ការសម្តែងឆន្ទៈនេះមាន

ប្រភេទ និងប្រភពខុសៗគ្នា គឺទីមួយ ជាលិខិតគតិយុត្ត ឬ សកម្មភាពគតិយុត្ត ដែលចែកចេញជាកិច្ចសន្យា ដូចជា កិច្ចសន្យាឯកតោភាគី កិច្ចសន្យាពហុភាគី និងកិច្ចសន្យារួម សេចក្តីចម្រើនដោយឥតហេតុ (ឧបកិច្ចសន្យា) និងសកម្មភាពឯកតោភាគីទីពីរ ដែលជាព្រឹត្តិការណ៍គតិយុត្ត (ពាក់ព័ន្ធនឹងអំពើអនីត្យានុកូល) និងទីបី បទប្បញ្ញត្តិដែលច្បាប់កំណត់។

**១. លំនាំបញ្ហានៃការស្រាវជ្រាវ**

ការរស់នៅរបស់សង្គមមនុស្ស គឺមិនដូចគ្នាទាំងស្រុងនោះទេ ហើយក៏មានលក្ខណៈខុសគ្នាទៅលើផ្នែកដូចជា សេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្តីស្រឡាញ់ មនោសញ្ចេតនារវាងគ្នានិងគ្នា។ ដោយសង្កេតឃើញពីសង្គមជាក់ស្តែងថា គ្រួសារខ្លះមានជីវភាពធូរធារ រស់នៅស្រួល ចំណែកគ្រួសារខ្លះក៏រកព្រឹកខ្វះល្ងាច មានជីវភាពក្រីក្រ។ ប៉ុន្តែទោះជាបែបនេះក្តី ក៏មានគ្រួសារមួយចំនួនគាត់មានជីវភាពធូរធារមែន ប៉ុន្តែដោយខ្វះនូវសមាជិក ខ្វះនូវក្តីស្រឡាញ់ ខ្វះនូវមនោសញ្ចេតនាមួយដែលកកក្តៅនោះគឺខ្វះកូន ដោយសារចង់មានកូន ករណីនេះអាចធ្វើការសុំកូនអ្នកដទៃ ឬសាច់ញាតិមកចិញ្ចឹម។ ចំណែកឯគ្រួសារខ្លះមានកូន ក្នុងនាមជាឪពុកម្តាយ គឺតែងមានគំនិតមួយចង់ឃើញកូនមានក្តីសុខ មានសុខភាពល្អ បានរៀនសូត្រ ចង់ឱ្យកូនក្លាយជាមនុស្សល្អក្នុងសង្គម។

ទោះបីគ្រួសារមួយចំនួនគាត់មិនមានវិវាទ ឬទំនាស់ ឬបញ្ហាផ្សេងៗក៏ដោយ តែគ្រួសារខ្លះគឺមានបញ្ហាដែលទាក់ទងនឹងរឿងសាច់ញាតិ សាច់សៃលោហិត។ ដោយសារបញ្ហាចំណងអាពាហ៍ពិពាហ៍ ហើយចំណងអាពាហ៍ពិពាហ៍នេះអាចជាអាពាហ៍ពិពាហ៍ស្របច្បាប់ ឬមិនស្របច្បាប់ (អនីតិសង្វាស) និងរួមដោយសារឪពុកម្តាយមិនមានការចុះសម្រុងគ្នា ហើយបង្កើតឱ្យមានការលែងលះ។ មួយវិញទៀត ក៏ដោយសារការបំបោះបំបង់កូនចោល ឬត្រូវបែកបាក់គ្នាដោយកត្តាអ្វីៗផ្សេងទៀត។

នៅក្នុងគ្រួសារដើម្បីបញ្ជាក់ពីសាច់ញាតិកើតឡើងនៅពេលណា ហើយមានអត្ថប្រយោជន៍យ៉ាងណា គឺអាចបង្ហាញតាមរយៈការបង្កើតជាបុត្តភាព។ ការបង្កើតបុត្តភាពវាមានសារៈសំខាន់ណាស់ ក្នុងការផ្សារភ្ជាប់ឪពុកម្តាយ និងកូន ហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីកម្ពុជាយើង បានចែងបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងបុត្តភាព។

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**

ដើម្បីស្វែងយល់ និងធ្វើការស្រាវជ្រាវអំពីប្រធានបទស្តីពី បុត្តភាព និងដើម្បីធ្វើការពន្យល់អំពីប្រធានបទនេះ គឺត្រូវលើកឡើងពីនូវបញ្ហាគតិយុត្តពីរ ដែលអាចឈានទៅដល់ការធ្វើការបែងចែកប្លង់៖

- តើបុត្តភាពបង្កើតឡើងនៅពេលណា?
- តើបុត្តភាពមានអានុភាពយ៉ាងដូចម្តេច?

### ៣. គោលបំណងនៃការស្រាវជ្រាវ

សារណានេះមានគោលបំណង ស្វែងយល់បន្ថែម និងចែករំលែកនូវចំណេះដឹងថ្មីៗ តាមរយៈការសិក្សាស្រាវជ្រាវ អំពីប្រធានបទស្តីពី បុត្តភាព។ មួយវិញទៀត ដើម្បីជួយជាដំណោះស្រាយនូវចំណោទបញ្ហារបស់មិត្តនិស្សិតទាំងឡាយដែលមានរាល់បញ្ហាចម្ងល់ពាក់ព័ន្ធនឹងរឿងឯកជនស្តីពីទំនាក់ទំនងឪពុកម្តាយ និងកូន។

### ៤. ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទស្តីពី បុត្តភាព នេះបើនិយាយដោយផ្អែកតាមនិយមន័យទៅ គឺវាមានលក្ខណៈធំទូលាយ ប៉ុន្តែដើម្បីជាការលម្អិតនឹងសង្កត់ធ្ងន់ទៅលើបញ្ហាមួយចំនួនដែលវាតែងតែជាចម្ងល់របស់បងប្អូន ទើបយើងខ្ញុំសូមធ្វើការកំណត់ដែនកំណត់នៃការស្រាវជ្រាវនេះ ដោយផ្តោតសំខាន់លើការបង្កើតអំពីបុត្តភាព និងអានុភាពនៃបុត្តភាពតែប៉ុណ្ណោះ ដើម្បីកុំឱ្យមានការភាន់ច្រលំទៅលើទំនាក់ទំនងគតិយុត្តផ្សេងទៀត។

### ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃសារណាមួយនេះ គឺអាចជាស្ពានឈាននាំផ្លូវដោយឆ្លុះបង្ហាញ ពន្លឺនូវចំណេះដឹងដល់រូបយើងខ្ញុំជាអ្នកស្រាវជ្រាវផ្ទាល់ ដល់មិត្តអ្នកអាន និងអ្នកស្រាវជ្រាវគ្រប់ជំនាន់ ក្នុងការយល់ច្បាស់ពីទំនាក់ទំនងគ្រួសារ ដែលហៅថា **បុត្តភាព**។ ជាពិសេសសម្រាប់អ្នកស្រាវជ្រាវដែលមានការខ្វះខាតនូវឯកសារពាក់ព័ន្ធនឹងមេរៀននីតិគ្រួសារ ហើយយើងខ្ញុំក៏សង្ឃឹមថា មិត្តអ្នកអាន និងអ្នកស្រាវជ្រាវទទួលបាននូវចំណុចពិសេសណាមួយទៅតាមតម្រូវការ ដើម្បីបំពេញបន្ថែមពុទ្ធិនិងកិច្ចការ នានា។

### ៦. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺយើងខ្ញុំពិតជាមានការស្វះស្វែងខ្លាំងណាស់ ដើម្បីរកឯកសារពាក់ព័ន្ធនឹងប្រធានបទស្តីពី **បុត្តភាព** ដោយក្នុងនោះយើងខ្ញុំទទួលបានមកពីប្រភពដូចជា៖

- ប្រភពទី១ យើងខ្ញុំទទួលបានពីការណែនាំ និងការបកស្រាយពន្យល់ពីលោក លោកស្រីសាស្ត្រាចារ្យផ្នែកច្បាប់ទាំងឡាយ រួមទាំងសិស្សច្បង ជាពិសេសនោះគឺទទួលបានលោក លោកស្រីសាស្ត្រាចារ្យណែនាំប្រធានបទសារណាមួយនេះ។
- ប្រភពទី២ បានមកពីបណ្ណាល័យ និងកាតាឡុកអេឡិត្រូនិចសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យអេឡិចត្រូនិចសាកលវិទ្យាល័យដទៃទៀត។
- ប្រភពទី៣ បានមកពីគេហទំព័រក្រសួងយុត្តិធម៌ និងChhanel Telegramនានា ដែលផ្សព្វផ្សាយ និងចែករំលែកអំពីឯកសារច្បាប់។
- ប្រភពទី៤ ដកស្រង់នូវខ្លឹមសារ ដែលទាក់ទងនឹងប្រធានបទទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើត ពីក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងក្រមរដ្ឋប្បវេណីចាស់នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៦៧។

### ៧. រចនាសម្ព័ន្ធការស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយទៅលើប្រធានបទ "**មុត្តនាព**" នេះឱ្យកាន់តែច្បាស់លាស់ និងឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនោះ យើងខ្ញុំបានធ្វើការបែងចែកប្រធានបទនេះជាពីរជំពូករួមមាន៖

**ជំពូកទី១៖ ការបង្កើតបុត្តភាព**

ជំពូកទី១នេះនឹងរៀបរាប់អំពីការបង្កើតបាននូវបុត្តភាព ដោយបែងចែកជាបីផ្នែក ដែលទាក់ទងមានដូចជា សញ្ញាណទូទៅនៃបុត្តភាព (ផ្នែកទី១) ការសម្រេចអំពីបុត្តភាព (ផ្នែកទី២) និងបណ្តឹងបញ្ជាក់អំពីអត្ថិភាពនៃបុត្តភាព (ផ្នែកទី៣)។

**ជំពូកទី២៖ អានុភាពនៃបុត្តភាព**

ជំពូកទី២នេះនឹងបង្ហាញអំពីអានុភាពនៃបុត្តភាព ដោយក្នុងជំពូកនេះមានបីផ្នែក និយាយអំពីអំណាចមេបា (ផ្នែកទី១) សិទ្ធិ និងករណីយកិច្ចរបស់របស់អ្នកមានអំណាចមេបា (ផ្នែកទី២) និងរួមទាំងបង្ហាញអំពីអាហារកាតព្វកិច្ច (ផ្នែកទី៣)។

# ជំពូកទី១
# ការបង្កើតនូវបុគ្គភាព

# ជំពូកទី១
# ការបង្កើតនូវបុត្តភាព

ទំនាក់ទំនងឪពុកម្តាយ និងកូន គឺជាលក្ខខណ្ឌដ៏សំខាន់ ដើម្បីបង្កើតជាបុត្តភាព គេត្រូវស្វែងយល់អំពីស្ថានភាពរបស់ឪពុកម្តាយនៅពេលចាប់កំណើតរបស់កូន ឬនៅពេលដែលមានគភ៌។ អាស្រ័យហេតុនេះ គេត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទដែលកូននោះចាប់កំណើតនៅក្នុងគភ៌។ ជាធម្មតា ការកំណត់កាលបរិច្ឆេទនៃកំណើតមិនសូវចោទជាបញ្ហានោះទេ ប៉ុន្តែចំពោះកាលបរិច្ឆេទនៃការមានគភ៌ត្រូវធ្វើការប៉ានប្រមាណប៉ុណ្ណោះ។ នៅពេលដែលកូនកើត អ្នកដែលជាឪពុកម្តាយ គឺមានករណីយកិច្ចក្នុងការប្តឹងសុំចុះសំបុត្រកំណើតឱ្យកូនទៅតាមការកំណត់របស់ច្បាប់។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃបុត្តភាព

### កថាខណ្ឌទី១ និយមន័យ

បុត្តភាព សំដៅលើទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់របស់ឪពុកម្តាយ ដែលយើងតែងហៅថាជាកូនបង្កើត។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ បានផ្តល់និយមន័យអំពីបុត្តភាពថា ដែលហៅថា បុត្តភាព គឺជាចំណងញាតិលោហិតផ្ទាល់ ដែលចងឪពុក ឬម្តាយ ឱ្យជាប់នឹងកូន ដែលកើតអំពីខ្លួន។[1]

បិតុភាព គឺជាក្រសែញាតិ ដែលទាក់ទងពីឪពុកទៅកូន។[2] នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ បានផ្តល់និយមន័យអំពីបិតុភាពថា បិតុភាព គឺជាចំណង ដែលចងឪពុកឱ្យជាប់នឹងកូន ហើយមាតុភាព គឺជាចំណងដែលចងម្តាយឱ្យជាប់នឹងកូន។

មាតុភាព សំដៅលើស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន។

### កថាខណ្ឌទី២ សំបុត្រកំណើត

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចកំណត់នៃច្បាប់ព្រះរាជាណាចក្រកម្ពុជា។ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ សំបុត្រអត្រានុកូលដ្ឋាន មានសារៈសំខាន់ណាស់សម្រាប់ពលរដ្ឋគ្រប់រូប។ ការចុះសំបុត្រអត្រានុកូលដ្ឋាន ធ្វើឱ្យបុគ្គលម្នាក់ៗទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម នយោបាយ និងករណីយកិច្ចនានា រួមមានសិទ្ធិក្នុងការបោះឆ្នោតនិងឈរឈ្មោះបោះឆ្នោត សិទ្ធិទទួលបានការអប់រំនិងការងារ សិទ្ធិទទួលបានយុត្តិធម៌ ការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិកាន់កាប់កម្មសិទ្ធិ។[3]

[1] មាត្រា ២៦០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៦៧។

[2] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០០៧ (ចូលជាធរមានចាប់ពី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), លេខរៀង ៨៤។

[3] ដកស្រង់ចេញពីសៀវភៅ តម្រង់ទិសវិជ្ជាជីវៈ «ឯកសារចំណេះដឹង អត្រានុកូលដ្ឋាន» របស់អង្គការស៊ីប៉ា។

ការចុះសំបុត្រកំណើត គឺជាការធ្វើលិខិតកំណត់ ដើម្បីសម្គាល់ពីអត្តសញ្ញាណរបស់បុគ្គល នោះមានន័យថា វាមានទំនាក់ទំនងនៅក្នុងការរស់នៅក្នុងសង្គម ដែលវាជាធាតុផ្សំចាំបាច់នៅពេលមានតម្រូវការ ឬមានបញ្ហាផ្សេងៗដែលត្រូវចាំបាច់ប្រើប្រាស់។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃខែឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើត មិនត្រូវឱ្យខុសពីថ្ងៃខែឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការ។[4]

### ១. រយៈពេល និងទីកន្លែងចុះសំបុត្រកំណើត

ជាទូទៅដើម្បីទទួលបាននូវការចុះសំបុត្រកំណើតនៅពេលមានទារកទើបនឹងកើត ឪពុកម្តាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៃទីលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ក្នុងរយៈពេល ៣០ (សាបសិប) ថ្ងៃក្រោយកំណើតទារក ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងទទួលបានសំបុត្រកំណើត។ សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតសម្រាប់ទារក គឺមិនត្រូវបានគិតប្រាក់ទេ។[5] បើសិនជាបានមកចុះសំបុត្រកំណើតកូន ក្នុងរយៈពេលកំណត់ ៣០ (សាបសិប) ថ្ងៃ ហើយមានឯកសារគ្រប់គ្រាន់ដូចខាងលើនេះ មេឃុំ ឬចៅសង្កាត់ ដែលជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ឱ្យទៅឪពុកម្តាយ។

យ៉ាងណាក៏ដោយ ទារកទាំងឡាយណាដែលកើតពីឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ពួកគេនៅតែត្រូវបានអនុញ្ញាតឱ្យចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើត។ ឪពុកម្តាយរបស់ទារកដែលទើបនឹងកើត តម្រូវបង្ហាញកូនរបស់ពួកគេចំពោះមុខមេឃុំ-សង្កាត់ ដើម្បីចុះអត្រានុកូលដ្ឋានកំណើត។ ប្រសិនបើទារកកើតពីឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ត្រូវបានប្រើប្រាស់ជាឯកសារភស្តុតាងបញ្ជាក់ភាពជាឪពុកម្តាយ។[6]

យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ (ស.ណ.ន ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧) ការចុះសៀវភៅកំណើតត្រូវនាំទៅជាមួយនូវលិខិតស្នាមមួយចំនួនៈ

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់ទារក ចេញដោយមន្ទីរពេទ្យ (ប្រសិនបើទារកកើតនៅមន្ទីរពេទ្យ)
- លិខិតបញ្ជាក់ទទួលស្គាល់កំណើត ចេញដោយមេភូមិ (ប្រសិនបើទារកកើតនៅផ្ទះ)

[4] មាត្រា ៤៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។

[5] ប្រកាសអន្តរក្រសួង លេខ ១៤៣៨៤២ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦។

[6] មាត្រា ២៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។

- ប្រសិនបើមាន ត្រូវយកទៅជាមួយផងដែរ នូវឯកសារមួយចំនួនទៀត ដូចជា សៀវភៅគ្រួសារ ដែលមានឈ្មោះឪពុកម្តាយរបស់ទារក សេចក្តីចម្លងសំបុត្រកំណើតរបស់ឪពុកម្តាយ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកម្តាយ អត្តសញ្ញាណប័ណ្ណរបស់ឪពុកម្តាយ។
- ក្នុងករណីឪពុកម្តាយមិនបានទៅចុះសៀវភៅកំណើតដោយផ្ទាល់ខ្លួនឯង ហើយពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងឱ្យទៅជំនួស ឪពុកម្តាយ ត្រូវធ្វើលិខិតបញ្ជាក់មួយទៀត ដោយមានបញ្ជាក់ច្បាស់លាស់ ពីនាមត្រកូល នាមខ្លួន និងថ្ងៃខែឆ្នាំកំណើតរបស់ទារក។

បើសិនជាកូនកើតមក មិនទៅចុះសំបុត្រកំណើត ទុកឱ្យហួស ៣០ថ្ងៃ ការចុះសំបុត្រកំណើត នៅតែអាចធ្វើបាន ប៉ុន្តែត្រូវបានធ្វើសំណុំបែបបទច្រើនជាងការទៅចុះសំបុត្រកំណើត ក្នុងរយៈពេលកំណត់ ហើយត្រូវមានការបង់ថ្លៃ។ ការសុំចុះសំបុត្រកំណើត ហួសពី ៣០ថ្ងៃ ក្រោយពីទារកកើត គឺត្រូវធ្វើទៅតាមនីតិវិធី ដែលគេហៅថា "ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋាន" ប៉ុន្តែធ្វើនៅសាលាឃុំសង្កាត់ដែលឪពុកម្តាយរស់នៅដដែល ដោយមិនចាំបាច់ត្រូវទៅដល់ស្រុកខណ្ឌ ឬក៏ខេត្តក្រុងទេ។[7]

ក្នុងការប្តឹងសុំចុះសំបុត្រកំណើតនេះ ឪពុក ឬម្តាយរបស់ទារកត្រូវមានសំណុំឯកសារ ដូចករណីចុះសំបុត្រកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃដែរ។ ប៉ុន្តែ ត្រូវនាំទៅជាមួយ នូវសាក្សី ២រូប ដែលជានីតិជន ហើយត្រូវបំពេញពាក្យប្តឹងសុំចុះសំបុត្រកំណើត។ ពាក្យប្តឹងសុំចុះសំបុត្រកំណើតនេះត្រូវបិទតែមប្រ៊ី ថ្លៃ ១ពាន់រៀល សម្រាប់ប្រជាពលរដ្ឋដែលរស់នៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ និងឧត្តរមានជ័យ។ សម្រាប់អ្នកនៅខេត្តផ្សេងក្រៅពីនេះ ត្រូវបិទតែមប្រ៊ីថ្លៃ ៤ (បួន) ពាន់រៀល។ ការទិញតែមប្រ៊ីនេះ គឺជំនួសឱ្យការបង់លុយផ្ទាល់ មានន័យថា អ្នកសុំមិនតម្រូវឱ្យបង់លុយអ្វីបន្ថែមពីលើនេះទៀតទេ។ ជារួមមកវិញ ប្រសិនបើទៅចុះសំបុត្រកំណើតទាន់ពេល គឺមិនហួសពី ៣០ថ្ងៃ ក្រោយពីទារកកើត សំណុំបែបបទមានលក្ខណៈងាយស្រួលជាង ហើយសំបុត្រកំណើតត្រូវចេញឱ្យដោយឥតគិតថ្លៃ។ ប៉ុន្តែ បើទុកឱ្យហួស ៣០ថ្ងៃ បានទៅចុះ គឺត្រូវបំពេញសំណុំបែបបទច្រើនជាង ហើយត្រូវមានបង់ថ្លៃ តាមរយៈការទិញតែមប្រ៊ី។[8]

### ២. ក្នុងករណីទារកកើតនៅបរទេស

ក្នុងករណីទារកកើតនៅបរទេសពីឪពុកម្តាយជាពលរដ្ឋខ្មែរ ហើយរស់នៅដោយស្របច្បាប់នៅបរទេស ឪពុក ម្តាយរបស់ទារកនេះ អាចទៅសុំចុះសំបុត្រកំណើតកូន នៅអាជ្ញាធរអត្រានុកូលដ្ឋានរបស់ប្រទេសដែលខ្លួនរស់នៅនោះបានទៅតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ។ បន្ទាប់មកទៀតគាត់អាចមានលទ្ធភាពពីរ ឬមួយ គាត់

[7] សិក្ខាសាលាស្តីពី ទំនាក់ទំនងឪពុកម្តាយ និងកូន រួមទាំងកូនស្មុំកូន, ក្រុមការងារគណៈមេធាវី, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។

[8] នាទីយល់ដឹងអំពីច្បាប់ និងជំនួញ, សេង ឌីណា, អំពីបែបបទនៃការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត (សំបុត្រកំណើត), ចុះផ្សាយនៅថ្ងៃ ២៨.០៣.២០១៣- ០៣:០០កែប្រែថ្ងៃទី២៨.០៣.២០១៣ -១៣:៥៥។

ទៅសុំចុះសំបុត្រកំណើត នៅឯស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជា ដែលប្រចាំនៅក្នុងប្រទេស ដែលគាត់រស់នៅនោះ។ ក្នុងករណីនេះ ស្ថានទូត ឬស្ថានកុងស៊ុលនឹងចេញសំបុត្រកំណើតច្បាប់ដើម ដែលអាចយកមកប្រើប្រាស់ជាផ្លូវការបានដូចសំបុត្រកំណើតដែលចេញដោយមេឃុំចៅសង្កាត់នៅក្នុងប្រទេសកម្ពុជាដែរ។ មួយទៀត ឪពុកម្តាយ មិនចាំបាច់ទៅសុំចុះសំបុត្រកំណើត នៅស្ថានទូត ឬស្ថានកុងស៊ុលកម្ពុជាក៏បានដែរ។ ក៏ប៉ុន្តែ នៅពេលគាត់វិល ត្រឡប់មកប្រទេសកម្ពុជាវិញ គាត់ត្រូវយកសំបុត្រកំណើត ដែលចេញដោយអាជ្ញាធរបរទេស ទៅបង្ហាញមេឃុំ ឬចៅសង្កាត់ នៃទីលំនៅថ្មីរបស់គាត់ ដើម្បីសុំសំបុត្រកំណើតថ្មី។[9]

### ៣. ការកំណត់នាមត្រកូលរបស់កូន

ការកំណត់នាមត្រកូលរបស់កូន អាចធ្វើឡើងបាន ៣យ៉ាង[10]៖

- អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយក៏បាន
- អាចយកឈ្មោះជីតាខាងឪពុកមកដាក់ជានាមត្រកូលក៏បាន
- ឬក៏អាចយកឈ្មោះរបស់ឪពុក មកដាក់ជានាមត្រកូលក៏បាន។

ចំពោះឈ្មោះរបស់ទារកវិញ (នាមខ្លួន) គឺឪពុកម្តាយ ឬអាណាព្យាបាលជាអ្នកដាក់ឱ្យ។ ការកំណត់ឈ្មោះ និងនាមត្រកូលរបស់ទារកនេះ គឺត្រូវធ្វើឡើង តាំងពីពេលចុះសំបុត្រកំណើត។ មែនទែនទៅ ឪពុកម្តាយត្រូវរកឈ្មោះដាក់ឱ្យកូន តាំងពីមុនចុះសំបុត្រកំណើតម្ល៉េះ ព្រោះបើកើតនៅមន្ទីរពេទ្យ លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យក៏ត្រូវមានកំណត់នាមត្រកូល និងនាមខ្លួនទារក។ បើកើតនៅផ្ទះ លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក ដែលចេញដោយមេភូមិ ក៏ត្រូវមានដាក់នាមត្រកូល និងនាមខ្លួនទារកដែរ។

## កថាខណ្ឌទី៣ ទំនាក់ទំនងបុត្តភាព

ទំនាក់ទំនងគ្រួសារ គឺនិយាយអំពីទំនាក់ទំនងប្តីប្រពន្ធរហូតដល់ទំនាក់ទំនងរវាងបុត្តភាព គឺជាបញ្ហាដែលសំខាន់ខ្លាំងដែលទាក់ទិនគ្នា។ បញ្ហាទីមួយ គឺនិយាយអំពីទំនាក់ទំនងបុត្តភាពតាមច្បាប់កើតឡើងត្រឹមកម្រិតណា? បុត្តភាពគឺមានទាំងករណីដែលឪពុកម្តាយ និងកូនមានទំនាក់ទំនងលោហិតនឹងគ្នា និងករណីដែលឪពុកម្តាយ និងកូនមិនមានទំនាក់ទំនងលោហិតនឹងគ្នាបញ្ហាទីពីរ គឺក្នុងករណីដែលទំនងទំនងបុត្តភាពតាមច្បាប់ត្រូវបានទទួលស្គាល់ហើយ តើខ្លឹមសារជាក់លាក់នៃទំនាក់ទំនងនោះជាខ្លឹមសារបែបណា? ជាពិសេស តើឪពុកម្តាយមានសិទ្ធិអំណាចប៉ុណ្ណាទៅលើកូននោះ? ទំនាក់ទំនងនៃបុត្តភាពគឺអាចមានឡើងរវាងកូនបង្កើត **(១)** ស្មុំកូន **(២)** និងកូនដែលបង្កើតតាមវេជ្ជសាស្ត្រ **(៣)**។

---

[9] នាទីយល់ដឹងអំពីច្បាប់ និងជំនួញ, សេង ឌីណា, អំពីបែបបទនៃការសុំចុះសៀវភៅអត្រានូកូលដ្ឋានកំណើត (សំបុត្រកំណើត), ចុះផ្សាយនៅថ្ងៃ ២៨.០៣.២០១៣- ០៣:០០កែប្រែថ្ងៃទី២៨.០៣.២០១៣ -១៣:៥៥។

[10] មាត្រា ១៨ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។

### ១. កូនបង្កើត

កំណើតជាព្រឹត្តការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គលពោល គឺជាការចាប់ផ្តើមកកើតនូវសិទ្ធ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឱ្យបានក្លាយជារូបវន្តបុគ្គលត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ ការកើតមកជាមនុស្ស ការកើតមកមានដង្ហើម ហើយរស់បាន។

ពាក្យថាកូនបង្កើត គឺជាកូនដែលមានសាច់ឈាមលោហិតខ្សែផ្ទាល់របស់ឪពុកម្តាយខ្លួន មិនថាឪពុកម្តាយមានទំនាក់ទំនងបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ក្តី ឬជាចំណងអាពាហ៍ពិពាហ៍អនីតិសង្វាសក្តី។ កូនដែលកើតចេញពីប្តីប្រពន្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គឺជាកូនមានខាន់ស្លារបស់ប្តីប្រពន្ធនោះ ហើយជា កូនដែលសម្រាលចេញពីម្តាយ។ ក្នុងនេះ កូនដែលកើតពីចេញពីឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ហៅថា កូនមានខាន់ស្លា ចំណែក កូនដែលកើតចេញពីឪពុកម្តាយមានចំណងទំនាក់ទំនងបែបអនីតិសង្វាសហៅថា កូនឥតខាន់ស្លា។

ការសន្មតថាជាកូនមានខាន់ស្លា គឺលុះត្រាតែកូននោះកើតក្នុងចិរវេលា ១៨០ថ្ងៃយ៉ាងតិច គឺត្រូវចាត់ទុកថាកូនដែលសម្រាលចេញពីម្តាយ ជាកូនរបស់ឪពុកជាប្តីនៃម្តាយ។ កូននឹងចាត់ទុកថា ជាកូនមានខាន់ស្លាបាន លុះត្រាតែកូនកើតពីម្តាយ ក្នុងរយៈពេល ៣០០ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍រវាងឪពុក និងម្តាយពីគ្នា។ រីឯកូនដែលកើតយ៉ាងតិច ១៨០ថ្ងៃ គឺសន្មតថាជាកូនឥតខាន់ស្លា ដោយមិនមែនកូនរបស់ឪពុកជាប្តីនៃម្តាយ។[11] ឧទាហរណ៍៖ ស្ត្រីម្នាក់បានរៀបអាពាហ៍ពិពាហ៍ហើយបានចុះសំបុត្រអាពាហ៍ជាមួយស្វាមីដែលបានរៀបអាពាហ៍ពិពាហ៍នោះ តែបន្ទាប់ពីស្ត្រីនោះបានរៀបអាពាហ៍ពិពាហ៍ហើយក៏បានសម្រាលកូន ហើយកូននោះកើតមុន១៨០ថ្ងៃ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយ នោះសន្មតថាកូននោះមិនមែនជាកូនរបស់បុរសដែលកំពុងមានចំណងអាពាហ៍ពិពាហ៍គតិយុត្តនឹងគ្នានោះទេ។ ប៉ុន្តែនៅក្នុងករណី ដែលថាកូននោះ គឺជាកូនរបស់បុរសកំពុងស្ថិតនៅក្នុងចំណងគតិយុត្ត លុះត្រាតែកូនបានកើតដោយឡើងពីការបង្កើតរវាងស្ត្រីនិងបុរសនោះ មុនអាពាហ៍ពិពាហ៍ កូននោះអាចចាត់ទុកជាកូនដែលមានខាន់ស្លានៅពេលឪពុកម្តាយរបស់ខ្លួនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ប៉ុន្តែបើមិនទាន់ចុះទេ កូននោះគឺកូនដែលឥតខាន់ស្លា។

### ២. សុំកូន

បុរស និងនារីដែលមានគោលបំណងរៀបអាពាហ៍ពិពាហ៍បង្កើតជាគ្រួសារមួយ គឺផ្តើមចេញសេចក្តីស្រលាញ់របស់អ្នកទាំងពីរ បន្ថែមពីនេះគោលបំណងចម្បងមួយទៀត នៃអាពាហ៍ពិពាហ៍ គឺការបង្កើតកូនសម្រាប់បន្តវង្សត្រកូល។ ប៉ុន្តែគ្រប់គ្រួសារទាំងអស់មិនប្រាកដថា នឹងអាចសម្រេចបាននូវគោលបំណងក្នុងការបង្កើតកូនបន្តពូជពង្សបាននោះទេ ដែលបញ្ហានេះភាគច្រើនកើតចេញពីកត្តាវេជ្ជសាស្ត្រ។ ក្នុងករណីដែលប្តី

[11] មាត្រា ៩៨៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

ប្រពន្ធនៃគ្រួសារមួយមិនអាចបង្កើតកូនដោយខ្លួនឯងបាន ពួកគេអាចស្វែងរកសុំកូនរបស់អ្នកដទៃ ឬកូនរបស់សាច់ញាតិខ្លួនឯងមកចិញ្ចឹមបាន ដែលសកម្មភាពនៃការសុំកូននេះ ក្នុងច្បាប់ត្រូវបានហៅថា ការសុំកូន។

ការសុំកូន គឺជាការសុំកូនរបស់អ្នកដទៃមកចិញ្ចឹមដោយស្របច្បាប់ ដើម្បីបង្កើតឱ្យមានទំនាក់ទំនងញាតិរវាងពួកគេ ពោលគឺធ្វើឱ្យទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ដូចគ្នាទៅនឹងឪពុកម្តាយ និងកូនបង្កើតដែរ។ ជាទូទៅ គោលបំណងនៃការសុំកូន គឺធ្វើឡើងព្រោះដោយសារតែះ

- បុគ្គលខ្លះដែលគ្មានទាយាទស្នងអាជីវកម្ម ត្រូវរកទាយាទស្នងបានតាមរយៈការសុំកូន។
- បុគ្គលដែលគ្មានទាយាទស្នងមរតក បន្តតំណែង ឬសន្តតិកម្មទ្រព្យសម្បត្តិជាអាទិ៍ ត្រូវរកទាយាទស្នងបានតាមរយៈសុំកូនអ្នកដទៃ ឬសុំកូននៅមណ្ឌលកុមារកំព្រា ឬក្មេងឯទៀតដែលមាននិស្ស័យជាមួយគ្នាជាដើម។
- អ្នកដែលអសមត្ថភាពគ្មានកូន ត្រូវការកូនដើម្បីអាចផ្តល់អាហារកិច្ច ឬមើលថែខ្លួននៅពេលចាស់ទៅ
- ស្វែងរកឪពុកម្តាយសម្រាប់កុមារកំព្រា ឬកុមារដែលខ្វះការថែរក្សា ឬការយកចិត្តទុកដាក់ពីឪពុកម្តាយបង្កើត។

អនុលោមតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន បានបើកផ្លូវដល់អ្នកដែលមានបំណង សុំកូន ឬសុំកូនគេមកចិញ្ចឹមដោយស្របច្បាប់ អាចធ្វើឡើងតាមរូបភាព ០២ (ពីរ) គឺះ

### ២.១ សុំកូនពេញលេញ

សុំកូនពេញលេញ គឺជាការសុំកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងតាមរយៈផ្លូវតុលាការ ដោយទាមទារឱ្យផ្តាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្តិ រវាងឪពុកម្តាយបង្កើត និងញាតិសន្តានរបស់កូនសុំនោះទាំងស្រុង ដើម្បីបង្កើតឱ្យមាននូវទំនាក់ទំនងញាតិនិងទំនាក់ទំនងគតិយុត្តរវាងឪពុកម្តាយចិញ្ចឹមនិងកូនសុំនោះវិញ។ ការដែលធ្វើបែបនេះ គឺដើម្បីឱ្យទំនាក់ទំនងរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំនោះ ដូចគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូនបង្កើតដែលច្បាប់បានទទួលស្គាល់។

គោលបំណងនៃសុំកូនពេញលេញខាងលើនេះ គឺធ្វើឡើងដើម្បីផ្តល់នូវគ្រួសារមួយ ដែលមានឪពុកម្តាយមានជីវភាពសមរម្យ និងអាចផ្គត់ផ្គង់គ្រប់គ្រាន់ដល់កុមារអភ័ព្វ (កូនសុំ) និងដើម្បីផលប្រយោជន៍កុមារដែលខ្វះការថែរក្សា ខ្វះសេចក្តីស្រឡាញ់ ខ្វះការយកចិត្តទុកដាក់ពីឪពុកម្តាយបង្កើត ឬឪពុកម្តាយបង្កើតមានជីវភាពក្រីក្រ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនបាន ឬដោយសារស្ថានភាពណាមួយ ដូចជាបញ្ហាវិបត្តិស្មារតី (អាចជាក្មេងកើតអង់ទីហ្ស៊ីម) ឬពិការភាពជាដើម។

ឪពុកម្ដាយចិញ្ចឹម អាចសុំកូនបានលុះត្រាតែបុគ្គលដែលមានសហព័ទ្ធ ដែលបានសហការ និងឯកភាពដោយព្រមព្រៀងថាធ្វើការសុំកូនយកមកចិញ្ចឹម។ ឪពុកម្ដាយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ។ ចំណែកកូនវិញ ជាគោលការណ៍ត្រូវមានអាយុយ៉ាងច្រើន ៨ (ប្រាំបី) ឆ្នាំ ទើបអាចស្នើសុំជាកូនស្មុំបាន។[12]

បន្ទាប់ពីមានលក្ខខណ្ឌដូចរៀបរាប់ខាងលើនេះហើយ ឪពុកម្ដាយចិញ្ចឹម ត្រូវតែមានឆន្ទៈសហការគ្នា និងធ្វើការព្រមព្រៀងដាក់ពាក្យសុំទៅកាន់តុលាការនៃទីលំនៅរបស់ឪពុកម្ដាយចិញ្ចឹមនោះ ដើម្បីឱ្យតុលាការចេញដីកាសម្រេចបង្កើតស្មុំកូនពេញលេញជូនទៅបុគ្គល (សហព័ទ្ធ) ដែលបានស្នើសុំ។

### ២.២ ស្មុំកូនធម្មតា

ស្មុំកូនធម្មតា គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូនអ្នកដទៃ និងឪពុកម្ដាយចិញ្ចឹមដែលបានសុំកូនអ្នកដទៃនោះយកមកចិញ្ចឹមបីបាច់ថែរក្សាដូចជាកូនរបស់ខ្លួនឯង បង្កើតតាមផ្លូវតុលាការ ប៉ុន្តែការស្មុំកូនធម្មតានេះមិនបានធ្វើឱ្យផ្ដាច់ទំនាក់ទំនងញាតិរវាងឪពុកម្ដាយបង្កើត និងកូនសុំនោះទេ ពោលគឺទំនាក់ទំនងញាតិរបស់ពួកគេនៅតែបន្តអត្ថិភាព នាំឱ្យពួកគេមានសិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកិច្ចគ្នាទៅវិញទៅមក។[13] ជាងនេះទៅទៀតកូនសុំនោះនៅតែជាសន្តតិជន (ទាយាទ) មានសិទ្ធិទទួលបានមរតករបស់ឪពុកម្ដាយបង្កើតរបស់គេដដែល។ ទន្ទឹមនឹងនេះកូនសុំក៏មានសិទ្ធិទទួលសន្តតិកម្មពីឪពុកម្ដាយដែលបានចិញ្ចឹម ពោលគឺឪពុកម្ដាយដែលបានស្មុំកូនធម្មតាផងដែរ។

បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចដាក់ពាក្យស្មុំកូនបាន។[14] ក្នុងករណីនេះ គឺត្រូវមានការចូលរួមដោយតុលាការផងដែរ ដើម្បីធ្វើការត្រួតពិនិត្យកុំឱ្យមានការបំពានលើការសុំកូនធម្មតា។ បុគ្គលដែលជាឪពុកម្ដាយចិញ្ចឹមមិនអាចស្នើសុំកូនចិញ្ចឹមដែលជាបុព្វញាតិខ្លួន ឬជនដែលមានអាយុច្រើនជាងខ្លួនបាននោះឡើយ។ ករណីកូនដែលសុំជា អនីតិជន អ្នកមានអំណាចមេបា ឬអាណាព្យាបាលរបស់អនីតិ-ជននោះ ត្រូវចូលរួមដាក់ពាក្យសុំជាមួយនឹងឪពុកម្ដាយចិញ្ចឹម ឬម្ដាយចិញ្ចឹម ឬឪពុកចិញ្ចឹម។

បន្ទាប់ពីមានលក្ខខណ្ឌដូចរៀបរាប់ខាងលើនេះហើយ ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ត្រូវមានឆន្ទៈដូចគ្នា និងព្រមព្រៀងដាក់ពាក្យសុំជាមួយគ្នាទៅកាន់តុលាការនៃទីលំនៅរបស់កូនសុំនោះ ដើម្បីឱ្យតុលាការចេញដីកាសម្រេចបង្កើតស្មុំកូនធម្មតា។ ប៉ុន្តែបើកូនសុំជាអនីតិជន ឪពុកម្ដាយចិញ្ចឹមត្រូវដាក់ពាក្យសុំជាមួយអ្នកមានអំណាចមេបា ឬអាណាព្យាបាល នៃកូនសុំនោះ ទៅកាន់តុលាការនៃទីលំនៅរបស់កូនសុំ។

[12] មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៦៧។

[13] មាត្រា ១០២៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៦៧។

[14] មាត្រា ១០២០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

អ្នកដាក់ពាក្យសុំមិនចាំបាច់ត្រូវតែជាអ្នកមានសហព័ទ្ធ (ប្តីប្រពន្ធស្របច្បាប់) នោះទេ ពោលគឺបុរស ឬនារីដែលនៅលីវ ក៏អាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានដែរ។ ប៉ុន្តែចំពោះអ្នកមានសហព័ទ្ធ (ប្តីប្រពន្ធស្របច្បាប់) ប្រសិនបើមានតែសហព័ទ្ធម្ខាង ដែលគាត់ចង់បានកូនចិញ្ចឹម ហើយគាត់បានដាក់ពាក្យសុំពុំបានសហការជាមួយសហព័ទ្ធម្ខាងទៀត នោះអានុភាពមានតែចំពោះតែអ្នកដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ។ មានន័យថា អ្នកដែលសុំ គឺជាអ្នកក្លាយជាម្តាយ ឬឪពុកចិញ្ចឹមលើកូននោះ។[15]

យ៉ាងណាមិញការសុំកូនអ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ ដែលយើងហៅថាការសុំកូននេះត្រូវតែធ្វើឡើងតាមផ្លូវតុលាការ ដូច្នេះការដែលចង់រំលាយការសុំកូននេះវិញ ក៏ត្រូវធ្វើឡើងតាមរយៈការកាត់កាលតាមផ្លូវតុលាការ ដូចគ្នាផងដែរ។

### ៣. កូនដែលកើតតាមវិធីវេជ្ជសាស្ត្រ

ការបង្កកំណើតតាមវិធីវេជ្ជសាស្ត្រ គឺជាវិធីដែលជួយអ្នកពិបាកនឹងមានកូន ដោយបង្កកំណើតតាមរយៈដាក់មេជីវិតញី និងមេជីវិតឈ្មោលឱ្យចួបគ្នាក្នុងមជ្ឈដ្ឋានពិសេសមួយ ដែលផ្តល់ឱកាសកកើតជាកោសិកាកូនដោយមានការកំណត់ពេលវេលា ។ កោសិកាកូនត្រូវបានត្រួតពិនិត្យ និងធ្វើចំណាត់ថ្នាក់ រហូតដល់ចែកជាកោសិកាច្រើន ឬឈានដល់ក្លាយជា កោសិកាកូនដែលមានអាយុប្រាំថ្ងៃ មុនពេលបញ្ចូលទៅក្នុងស្បូនម្តាយវិញ។ ដំណើរការទាំងអស់នៃការបង្កកំណើតក្នុងកែវមានដូចជា ការពិនិត្យ និងការភ្ញោចមេជីវិតញីឱ្យទុំល្អ ការបូមយកមេជីវិតញីពីខ្លួនម្តាយ និងការបញ្ចូលកោសិកាកូនបញ្ចូលទៅក្នុងស្បូនវិញ ដើម្បីយកកោសិកាមេជីវិតឈ្មោល និងមេជីវិតញី ទៅដាក់នឹងស្បូនរបស់ស្ត្រីណាមួយផ្សេងទៀត (យោងតាម website Very well Family ស្តីពី In Vitro Fertilization (IVF): What to Expect)។ ដំណើរការនេះត្រូវបានធ្វើនៅមន្ទីរសម្រាកព្យាបាល ដោយប្រើនូវសម្ភារដ៏ទំនើប។ ដំបូងឡើយ ការបង្កកំណើតក្រៅស្បូន ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីជួយស្ត្រី ដែលមានជំងឺដៃស្បូន ដែលមិនអាចពពោះតាមធម្មជាតិបាន។ សព្វថ្ងៃបច្ចេកវិទ្យានេះ ត្រូវបានប្រើប្រាស់ដើម្បីព្យាបាលការលំបាកមានកូនដែលមានមូលហេតុច្រើនយ៉ាង។

ថ្វីដ្បិតតែបច្ចេកវិទ្យាទំនើប អាចធ្វើឱ្យមនុស្សបង្កើតកូនក្រៅខ្លួនបានក៏ពិតមែន ប៉ុន្តែនៅមិនទាន់ឃើញបទដ្ឋានគតិយុត្តមួយជាក់លាក់ ដែលបញ្ជាក់ថាមានការទទួលស្គាល់កូនដែលកើតឡើងនៅក្រៅស្បូនស្ត្រីជាម្តាយ ដោយមិនបានសម្រាលដោយផ្ទាល់។ ទោះបីជា មានការបញ្ចូលរួមគ្នារវាងមេជីវិតឪពុក និងអូវុលរបស់ម្តាយក៏ដោយ។ យ៉ាងណាមិញ នៅកម្ពុជាក៏មានអ្នកដែលមានកូន ដែលត្រូវបង្កើតឡើងតាមវេជ្ជសាស្ត្រពេទ្យនៅប្រទេសក្រៅផងដែរ។

[15] មាត្រា ១០៣៥ នៃក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៦៧។

ទោះជាយ៉ាងនេះក្តី ក្រមរដ្ឋប្បវេណីមិនបានបញ្ញត្តិចែងអំពីការបង្កើតកូនតាមវិធីវេជ្ជសាស្ត្រនោះឡើយ។ នៅប្រទេសបារាំង និងនៅប្រទេសអាល្លឺម៉ង ដោយសារតែផ្ទុយទៅនឹងសីលធម៌។ ដោយសារតែច្បាប់កំណត់ថា ស្រ្តី ដែលផ្តល់កំណើតឱ្យកូនជាម្តាយរបស់កូននោះ មានន័យថា ប្រពន្ធដែលស្នើសុំឱ្យស្រ្តីផ្សេងបង្កើតកូននោះ នឹងមិនក្លាយជាម្តាយបង្កើតរបស់កូននោះឡើយ ហើយករណីនេះ នឹងបង្អាក់ការអនុវត្តការបង្កើតកូនតាមបែប សិប្បនិម្មិតបែបនេះ ក៏ព្រោះតែ ដើម្បីបង្កើតបុត្តភាពរវាងប្តីប្រពន្ធដែលបានស្នើឱ្យស្រ្តីផ្សេងបង្កើតកូននិងកូនដែល កើតពីស្រ្តីនោះចាំបាច់ត្រូវបង្កើតសុំកូន។[16] ដូចក្រមរដ្ឋប្បវេណណីបានចែងនៅក្នុងមាត្រា ៩៨៧ អំពីមាតុភាព ហើយថា ស្រ្តីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន។

ប៉ុន្តែដើម្បីកំណត់អំពីបុត្តភាពនៅក្នុងករណីកូនកើតឡើងតាមវិធីវេជ្ជសាស្ត្រនេះ យោងតាមគោល ការណ៍ណែនាំរបស់កម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សលេខ ០៨៥/០១៧ ចុះនៅថ្ងៃទី០២ ខែ មិថុនា ឆ្នាំ២០១៨ ប៉ុន្តែគោលការនៃនីតិវិធីស្នើសុំទារកយកទៅក្រៅប្រទេសសម្រាប់អ្នកដែលអះអាងថាជាឪពុក គឺអនុវត្តត្រឹមតែថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ តែប៉ុណ្ណោះ។ សូមបញ្ជាក់ថា ដោយសារតែធ្លាប់ករណីពពោះជំនួស នៅក្នុង២០១៧ ហើយច្បាប់គតិយុត្តមិនទាន់មាននៅឡើយ អាចថាការអនុញ្ញាតឱ្យមានការធ្វើទិដ្ឋាការទារកបាន ជាករណីលើកលែង។ ដោយឡែកនៅប្រទេសកម្ពុជាពុំទាន់មានបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងបញ្ហានេះនៅឡើយទេ។ ហើយការស្រាវជ្រាវលើចំណុចនេះ នៅមានបញ្ហារឿងប្រភព និងពិបាកនឹងលើកទឡ្ហីករណ៍យកមកជាសំអាង។

### ផ្នែកទី២៖ ការសម្រេចអំពីបុត្តភាព

ជាទូទៅស្រ្តីដែលបានសម្រាលកូន ច្បាប់បានកំណត់ថា កូននោះជាកូនបង្កើតរបស់ម្តាយ និងជាកូន បង្កើតរបស់ឪពុក ដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬស្ថិតក្នុងអំឡុងពេលមួយដែលច្បាប់បានកំណត់ថាជា ឪពុករបស់កូន។ ក៏ប៉ុន្តែប្រសិនបើមិនអាចសន្មតជនដែលត្រូវជាឪពុករបស់កូនបានទេ នោះកូន ឬអ្នកតំណាង របស់កូន ត្រូវធ្វើការបញ្ជាក់ពីបិតុភាពរបស់កូន បានតាមផ្លូវច្បាប់។ និយាយអំពីមាតុភាព ស្រ្តីដែលបានសម្រាល កូន គឺជាម្តាយ។[17] ទាក់ទងនឹងបិតុភាពវិញ បុរសដែលបានផ្តល់មេជីវិតដើម្បីការបង្កកំណើតរបស់កូន គឺជា ឪពុក។ វាជាការងាយស្រួលសម្រាប់ម្តាយក្នុងការបញ្ជាក់ថាគាត់មានទំនាក់ទំនងជាមួយនឹងកូន ដោយសារតែ គាត់អាចទទួលបានសំបុត្របញ្ជាក់កំណើតជាមួយគ្នានឹងមានរបាយការណ៍អំពីកំណើត នោះឈ្មោះរបស់គាត់ នឹងត្រូវបានចុះនៅលើសំបុត្រកំណើត។

ក្នុងករណីដែលអ្នកជាម្តាយបានបាត់ខ្លួនអស់រយៈពេលយូរក្រោយពីបានសម្រាលកូនហើយ នោះគាត់ មិនងាយនឹងធ្វើការបញ្ជាក់ពីអង្គហេតុថាគាត់បានសម្រាលកូននោះឡើយ។ រីឯឪពុកវិញបើគាត់ជាអនីតិសង្វាស

[16] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា ៩៨៧។

[17] មាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

ជាមួយនឹងម្តាយ គឺគាត់ស្ថិតនៅក្រោមការសន្មតថា តើគាត់ជាឪពុករបស់កូនដែរ ឬទេ? ប្រសិនបើក្នុងសំបុត្រកំណើតកូនបានចុះដាក់ឈ្មោះអ្នកផ្សេងជាឪពុក ឬម្តាយ ដំណោះស្រាយ គឺការបដិសេធបិតុភាព។

ចំពោះឪពុកដែលមានបំណងទទួលស្គាល់កូនដោយស្ម័គ្រចិត្ត ច្បាប់បានអនុញ្ញាត ក៏ប៉ុន្តែត្រូវមានការយល់ព្រមពីម្តាយរបស់កូនជាមុនប្រសិនបើកូនជាអនីតិជន តែបើកូនជានីតិជនត្រូវមានការយល់ព្រមពីកូនដោយផ្ទាល់ ហើយបែបបទនៃទម្រង់ការទទួលស្គាល់នេះ ត្រូវធ្វើការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬតាមរយៈមតកសាសន៍ (ការយល់ព្រមរបស់ម្តាយត្រូវមាន ការចុះហត្ថលេខាលើលិខិតទទួលស្គាល់)។ តែផ្ទុយទៅវិញ ក្នុងករណីដែលឪពុក ឬកូន បានដឹងថាមិនមែនជាឪពុកកូនបង្កើត ជនដែលត្រូវបានសន្មតថា ជាឪពុក ឬជាកូនអាចមានសិទ្ធិបដិសេធចំពោះបិតុភាពបានចំពោះឪពុកដែលមានបំណងទទួលស្គាល់កូនដោយស្ម័គ្រចិត្ត ច្បាប់បានអនុញ្ញាត ក៏ប៉ុន្តែត្រូវមានការយល់ព្រមពីម្តាយរបស់កូនជាមុនប្រសិនបើកូនជាអនីតិជន តែបើកូនជានីតិជនត្រូវមានការយល់ព្រមពីកូនដោយផ្ទាល់ ហើយបែបបទនៃទម្រង់ការទទួលស្គាល់នេះ ត្រូវធ្វើការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬតាមរយៈមតកសាសន៍ (ការយល់ព្រមរបស់ម្តាយត្រូវមាន ការចុះហត្ថលេខាលើលិខិតទទួលស្គាល់)។ តែផ្ទុយទៅវិញ ក្នុងករណីដែលឪពុក ឬកូន បានដឹងថាមិនមែនជាឪពុកកូនបង្កើត ជនដែលត្រូវបានសន្មតថា ជាឪពុក ឬជាកូនអាចមានសិទ្ធិបដិសេធចំពោះបិតុភាពបាន។

**កថាខណ្ឌទី១ អំពីមាតុភាព**

ការបង្កើតឱ្យមាននូវមាតុភាពដោយផ្អែកលើអង្គហេតុច្បាស់លាស់យ៉ាងជាក់ស្តែង នាំឱ្យកំណត់ថាម្តាយដែលបានសម្រាលកូនដោយព្រមពេលជាមួយគ្នានឹងកំណើតរបស់កូន។ ហេតុដូច្នេះ យ៉ាងហោចណាស់ក៏ឪពុក ឬម្តាយម្នាក់របស់កូនត្រូវបានកំណត់ដែរ ដើម្បីទ្រទ្រង់ដល់សុខុមាលភាពរបស់កូននោះ។ អ្វីដែលនឹងអាចក្លាយជាបញ្ហានាពេលអនាគតនោះ គឺការសម្រាលកូនតាមបែបសិប្បនិមត្ត (Surrogate)។ ដោយសារការរីកចម្រើននៃបច្ចេកវិទ្យាវេជ្ជសាស្ត្រក្នុងការផ្តល់កំណើតទារក ការផ្តល់កំណើតកូនខាងក្រៅរាងកាយ (Invitriol fertilization) ត្រូវបានធ្វើឡើងនៅក្នុងប្រទេសខ្លះដោយប្រើមេជីវិតឈ្មោល (សក្កាណូ) របស់ប្តី និងអូវុលរបស់ប្រពន្ធ។ ហើយមេជីវិតដែលបានពីនោះត្រូវបានដាក់បញ្ចូលទៅក្នុងស្បូននៃស្ត្រីផ្សេង ដែលមិនមែនជាប្រពន្ធនោះ ដើម្បីធ្វើឱ្យមានគភ៌ ដោយពពោះជំនួសស្ត្រីដែលជាប្រពន្ធតែប៉ុណ្ណោះ។ ស្ត្រីដែលពពោះជំនួសមិនមែនជាសាច់ឈាមជាមួយនឹងកូនដែលខ្លួនបានសម្រាលនោះទេ។ កូនដែលសម្រាល គឺជាកូនរបស់ប្តីប្រពន្ធដែលជួលឱ្យស្ត្រីនោះជាអ្នកពពោះជំនួស។ តែសាច់សែលោហិត គឺជាកូនរបស់ប្តីប្រពន្ធមួយគូនោះសុទ្ធសាធ។ ចំណុចនេះធ្វើឱ្យយើងមានការសង្ស័យថា តើត្រូវដោះស្រាយបែបណានឹងត្រូវអនុវត្តចំពោះករណីដែលការបន្តពូជមានការផ្តល់ជំនួយផ្នែកវេជ្ជ-សាស្ត្រដូចជាការផ្សំអូវុល និងស្ពែម៉ាតូសូអ៊ីតនៅក្នុងបំពង់កែវជាដើម។

## កថាខណ្ឌទី២ អំពីបិតុភាព

ការបញ្ជាក់ពីបិតុភាពរបស់កូនមានបីរបៀប[18]៖

- ការសន្មតទៅលើទារក ដែលនៅក្នុងគភ៌ប្រពន្ធដែលស្ថិត ក្នុងចំណងនៃអាពាហ៍ពិពាហ៍ជាកូនរបស់ប្តី។ ការអាចបញ្ជាក់អំពីបិតុភាព គឺត្រូវមើលលើគភ៌របស់ស្ត្រីជាប្រពន្ធថា តើនាងមានគភ៌កំឡុងពេលរៀបអាពាហ៍ពិពាហ៍ ឬអត់?
- កូនដែលកើតក្រោយអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែល អាពាហ៍ពិពាហ៍បានបង្កើត ឬអំឡុងពេល ៣០០ថ្ងៃគិតចាប់ពីថ្ងៃបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ត្រូវបានសន្មតថា មានគភ៌អំឡុងពេលអាពាហ៍ពិពាហ៍។
- ប្រសិនស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី នោះប្រសិនបើមិនអាចកំណត់ឪពុករបស់កូនបាន ត្រូវសន្មតថាជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ថ្មី។ បើស្ត្រីនោះមានកូនជាមួយបុរសផ្សេងហើយ គឺមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានឡើយ។

### ១. ការសន្មតបិតុភាព

ការសន្មតបិតុភាព គឺធ្វើឡើងដើម្បីការពារប្រយោជន៍ជនជាឪពុក។ កាលណាបើទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តីដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា។ តែបើករណីកូនកើតមុនកាលកំណត់ មូលហេតុដោយសារតែការរីកចម្រើននៃវេជ្ជសាស្ត្រក្នុងការថែទាំទារក ដែលកើតក្រោយពេលមានផ្ទៃពោះ ៥ ខែ ក៏អាចរស់រានមានជីវិតដែរ។ មានន័យថា ក្រោយពេលដែលបានរៀបអាពាហ៍ពិពាហ៍រួចភ្លាម ម្តាយមានផ្ទៃពោះភ្លាមៗ ហើយកូននោះកើតក្នុងអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីរៀបអាពាហ៍ពិពាហ៍។ កូនដែលត្រូវចុះបញ្ជីថាជាកូនរបស់ប្តីប្រពន្ធនោះ ហើយការទទួលការចុះបញ្ជីបែបនោះមិនបង្កផលអាក្រក់អ្វីទេ។[19] ផ្ទុយទៅវិញ ដោយសារតែបិតុភាពមិនត្រូវបានសន្មតទេ ការបដិសេធបិតុភាព ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព។

នៅក្នុងករណីកូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬក្នុងអំឡុងពេល ៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាមានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។ បើសិនករណីប្តីបានទទួលមរណភាព កូនគួរតែបានចុះកំណើតថាជាកូនរបស់ប្រពន្ធ ហើយបិតុភាពជាមួយប្តីដែលទទួលមរណភាព ត្រូវបានបង្កើតឡើងតាមរយៈបណ្តឹងទាមទារឱ្យទទួលស្គាល់នៅក្រោយមរណភាព ដោយសារតែកូនកើតក្រោយអំឡុងពេលនៃការសន្មត

[18] មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៦៧។

[19] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។

បិតុភាព។ ដោយឡែក នៅមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ តាក់តែងឡើងដើម្បីជៀសវាងការប្រកួតប្រជែងការសន្មតឪពុកដោយអំឡុងពេលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មី។

### ២. ការបដិសេធបិតុភាព

ការសន្មតបិតុភាព ដែលបានកើតឡើងដោយជនដែលត្រូវបានសន្មតថាជាឪពុកជាអាទិ៍ ចំពោះកូនដែលបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។ កូនដែលបានកើតមុនកាលបរិច្ឆេទនៃការអនុវត្ត អាចដាក់ពាក្យប្ដឹងបដិសេធបិតុភាពបាន ដោយផ្អែកលើបញ្ញត្តិមាត្រា ៩៩១ (បណ្ដឹងបដិសេធបិតុភាព ពីកូន) នៃក្រមរដ្ឋប្បវេណី ចំពោះជនដែលត្រូវសន្មតថាជាឪពុក។ ប៉ុន្តែការសន្មតបិតុភាពក្នុងករណីនេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ដោយ។ ចំពោះលក្ខណសម្បត្តិរបស់ជនដែលអាចដាក់ពាក្យប្ដឹងបដិសេធបិតុភាពបាន នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រម រដ្ឋប្បវេណី។ ប៉ុន្តែ ក្នុងករណីដែលទាយាទរបស់ជនដែលត្រូវបានសន្មតថាជាឪពុក បានដាក់ពាក្យប្ដឹងបដិសេធបិតុភាពសម្រាប់ជននោះ នៅមុនកាលបរិច្ឆេទនៃការអនុវត្តបានដែរ។

#### ២.១ បណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវសន្មតថាជាឪពុក

ជនដែលត្រូវបានសន្មតថាជាឪពុករបស់កូន អាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន។ ការដាក់បណ្ដឹងបដិសេធបិតុភាពនេះ ត្រូវធ្វើឡើងដោយជនដែលសន្មតថាជាឪពុក ក្នុងអំឡុងពេលពេល ៦ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងពីកំណើតរបស់កូន។ បើជនដែលបានសន្មតថាជាឪពុក ជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅអាចដាក់ពាក្យបណ្ដឹងជំនួសបាន ក្នុងអំឡុងពេល ៦ខែ គិតចាប់ពីពេលដែលដឹងពីកំណើតរបស់កូន ឬជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅខ្លួនឯងអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន ទោះជាហួសអំឡុងពេលកំណត់រយៈពេល ៦ខែក៏ដោយ។ ប៉ុន្តែត្រូវធ្វើក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីថ្ងៃដែលលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅនោះ (មាត្រា ២៧ ក្រមរដ្ឋប្បវេណី)។

ករណីជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាពមុនកំណើតរបស់កូន ដោយមិនមានការដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬសាច់ញាតិលោហិតថ្នាក់ទីបី របស់ជនដែលត្រូវសន្មតថាជាឪពុកអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលជនត្រូវបានសន្មតថាជាឪពុកបានទទួលមរណភាព។ មានន័យថាកូននោះមិនមែនជាកូនរបស់ជនដែលត្រូវបានសន្មតថាជាឪពុក ហើយត្រូវទទួលបានសន្តតិកម្មពីបុរស ដែលត្រូវសន្មតថាជាឪពុក ដូច្នេះញាតិថ្នាក់ទី៣ អាចប្ដឹងបដិសេធបិតុភាព។ ក្នុងករណី ជនដែលបានត្រូវសន្មតថាជាឪពុកបានទទួលមរណភាពក្រោយពេល បានដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ជនដែលអាចដាក់ពាក្យបណ្ដឹងបដិសេធ

បិតុភាព គឺអាចជាសាច់ញាតិថ្នាក់ទីបី របស់ជនដែលសន្មតថាជាឪពុកដោយទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះ បានក្នុងអំឡុងពេល១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃឪពុកនោះទទួលមរណភាព។[20]

មរណភាពរបស់ម្តាយ នៅមុនពេលដាក់ពាក្យបណ្តឹង បញ្ហាដែលប្តីចង់ដាក់ពាក្យបណ្តឹងបដិសេធបុត្តភាព។ ប៉ុន្តែម្តាយរបស់កូនបានទទួលមរណភាពទៅហើយ ហើយពុំមានអាណាព្យាបាលសម្រាប់អនីតិជនទៀត។ កូននៅមានអាយុ ០ឆ្នាំ នៅឡើយ។ ក្នុងករណីនេះ ប្តីត្រូវដាក់ពាក្យសុំឱ្យជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន (មាត្រា៣២ នៃក្រមនីតិវិធី) ព្រោះកូន គឺជាជនខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (មាត្រា១៨ នៃក្រម-រដ្ឋប្បវេណី មាត្រា ៣២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ២.២ បណ្តឹងបដិសេធបិតុភាពពីកូន

មិនមែនមានតែឪពុកនោះទេ ដែលអាចប្តឹងបដិសេធបិតុភាព ចំពោះកូនក៏អាចប្តឹងបដិសេធបិតុភាពបានដែរ ប្រសិនបើកូនជា អនីតិជន ត្រូវមានម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើជាអ្នកតំណាងក្នុងការដាក់ពាក្យបណ្តឹងបដិសេធបិតុភាពនេះ តែបើមិនមានទេ នោះតុលាការនឹងជ្រើសតាំងអ្នកតំណាងពិសេស។ បណ្តឹងបដិសេធបិតុភាពពីកូននឹងមិនអាចអនុវត្តបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំរដ្ឋ) ខែ បានកន្លងផុតគិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន។ ប៉ុន្តែប្រសិនបើកូននោះ ស្ថិតនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគិតចាប់ពីពេលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ (មាត្រា៩៩១ នៃក្រមរដ្ឋប្បវេណី)។

ក្នុងករណីកូនបានទទួលមរណភាព ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធនូវបិតុភាពមុននឹងក្លាយជានីតិជន ឬដោយមិនបានដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ នោះកូនមិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ។ ប៉ុន្តែបច្ឆាញាតិរបស់កូនដែលទទួលមរណភាព (ជាចៅរបស់ឪពុករបស់កូនដែលបានទទួលមរណភាព) អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន គឺក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ។ ក្រោយពីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះបានក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីចាប់ថ្ងៃ ដែលកូនបានទទួលមរណភាព។ ស្របជាមួយគ្នានេះ ការទទួលបន្តនូវនីតិវិធីបណ្តឹង មិនអាចផ្អាកបានទេដូចមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា ១៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[21]

---

[20] មាត្រា ២៤ នៃច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។

[21] មាត្រា ២៦ នៃច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។

## ២.៣ អានុភាពប្រតិសកម្មនៃបណ្តឹងបដិសេធបិតុភាព

ប្រសិនបើមានសេចក្តីសម្រេចបដិសេធបិតុភាព អំពីបណ្តឹងបដិសេធបិតុភាព នោះមានន័យថាឪពុកដែលបានសន្មតថាជាឪពុករបស់កូននោះ មិនមែនជាឪពុករបស់កូននោះតាំងពីកូនចាប់បដិសន្ធិក្នុងគភ៌ម្តាយ។ ឧទាហរណ៍ មានប្តីប្រពន្ធពីរនាក់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា បន្ទាប់មកប្រពន្ធបានសម្រាលកូន ដែលមិនមែនជាកូនរបស់ប្តី ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយ ប៉ុន្តែត្រូវបានសន្មតថាជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍នោះ។ កន្លងមកទៀត ប្តីនោះត្រូវបានទទួលមរណភាព ម្តាយរបស់បុរសជាប្តីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាពចំពោះកូននោះ ការទាមទារនេះត្រូវបានទទួលស្គាល់ដោយតុលាការ។ ដោយសារតែអានុភាពប្រតិសកម្មនៃសាលក្រមនេះ កូននោះត្រូវបានចាត់ទុកថាមិនមែនជាកូនរបស់បុរសជាប្តីដែលទទួលមរណភាពនោះឡើយ។ ក្នុងករណីនេះ ឪពុកបង្កើតអាចទទួលស្គាល់បានលុះត្រាតែបានប្តឹងបដិសេធបិតុភាពចំពោះឪពុលស្របច្បាប់។

កាលបើបុរសជាប្តីនៅរស់បានធ្លាប់ផ្តល់អាហារកាតព្វកិច្ចដល់កូននិងប្រពន្ធ ទោះបីជាឪពុកនោះមិនមែនជាបុគ្គលដែលត្រូវមានករណីផ្តត់ផ្គង់ក៏ដោយ នោះវាជាសេចក្តីចម្រើនដោយឥតហេតុ ព្រោះបុគ្គលនោះជាឪពុកតាមច្បាប់ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយម្តាយបង្កើតកូននោះ។

### ៣. អំពីការទទួលស្គាល់

ការទទួលស្គាល់ គឺជាមធ្យោបាយមួយសម្រាប់ឪពុកដែលមិនបានត្រូវសន្មតថាជាឪពុក ដើម្បីបានចុះសំបុត្រកំណើត។ ល្គឹកណាបិតុភាពមិនត្រូវបានសន្មត វិធីកំណត់បិតុភាពគឺការទទួលស្គាល់។ ការដែលអាចទទួលស្គាល់កូនបាន លុះត្រាតែកូននោះគ្មានឪពុកតាមច្បាប់ មានន័យថា ប្រសិនបើកូនដែលកើតនោះមានឪពុក ដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយម្តាយនៃកូននោះហើយ ទោះបីជាឪពុកតាមច្បាប់មិនមែនជាឪពុកបង្កើតក៏ដោយ ឱ្យតែឪពុកតាមច្បាប់បានទទួលស្គាល់កូននោះថាជាកូនខ្លួនតាំងពីកើតមកហើយ បុរសដែលជាឪពុកបង្កើតមកទទួលស្គាល់ជាក្រោយ គឺពុំបានឡើយ។

ជាទូទៅ ការទទួលស្គាល់ក៏អាចកើតឡើងចំពោះម្តាយដែរ ប៉ុន្តែដោយសារតែម្តាយត្រូវបានបង្កើតឡើងដោយផ្អែកលើហេតុការណ៍កំណើតរបស់កូន។ ដូច្នោះ ទើបភាគច្រើននៃការទទួលស្គាល់គឺសំដៅលើការទទួលស្គាល់ដែលមានតែឪពុក។ ការទទួលស្គាល់អាចធ្វើឡើងដោយការស្ម័គ្រចិត្ត[22] ឬការទទួលស្គាល់ដោយបង្ខំ។ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត ត្រូវធ្វើឡើងដោយមានការស្ម័គ្រចិត្តពីឪពុកតាមរយៈការដាក់នូវទម្រង់ទទួលស្គាល់ជូនមន្ត្រីអត្រានុកូលដ្ឋាន ដែលបុរសជាឪពុកស្ម័គ្រចិត្តទទួលស្គាល់កូន ដើម្បីក្លាយខ្លួនក្នុងនាមជាឪពុកស្របច្បាប់។ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត គឺជាការទទួលស្គាល់ដែលកើតឡើងដោយឆន្ទៈផ្ទាល់របស់ឪពុក។

---

[22]មាត្រា ៩៩៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ការទទួលស្គាល់បិតុភាពដោយបុគ្គលជាឪពុក បើឪពុកនោះជាអនីតិជន ឬជាជនស្ថិតក្រោមអាណាព្យាបាលទូទៅមិនអាចទទួលស្គាល់កូនដែលក្នុងគភ៌ ដែលជាអនីតិជនបានទេ គឺត្រូវមានការយល់ព្រមពីកូន។ ក៏ប៉ុន្តែមិនអាចទទួលស្គាល់កូនរបស់ខ្លួនបានទេ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ។ ម្យ៉ាងទៀត អ្នកជាឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបានដោយពុំចាំបាច់មានការយល់ព្រមពីបច្ឆាញាតិផ្ទាល់។ ការធ្វើបែបនេះចង់បញ្ជាក់ថាបច្ឆាញាតិ គឺជានីតិជន ដែលគាត់អាចកំណត់ថាជនណាជាឪពុករបស់កូនដែលបានទទួលមរណភាពទៅនោះ។ ការទទួលស្គាល់ត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬក៏ធ្វើការទទួលស្គាល់តាមមរតកសាសន៍ក៏បានដែរ។ ឪពុកដែលបានទទួលស្គាល់កូនហើយ មិនអាចលុបចោលការទទួលស្គាល់នោះបានទេ ហើយការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះមក។ ប៉ុន្តែការទទួលស្គាល់នេះ មិនអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចទើយ (មាត្រា ៩៩៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

ចំណែកឯ ការទទួលស្គាល់ដោយបង្ខំ គឺជាការដាក់ពាក្យបណ្ដឹងរបស់កូនចំពោះឪពុក ដើម្បីបង្ខំឱ្យឪពុកទទួលស្គាល់ខ្លួនជាកូន។ នៅក្នុងបណ្ដឹង គឺទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្ដឹង ដោយយកឪពុកមកជាចុងចម្លើយ។ តែបើឪពុកត្រូវបានទទួលមរណភាព គឺត្រូវយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ។ ប្រសិនបើឪពុកបានទទួលមរណភាពក្នុងអំឡុងពេល ដែលតុលាការកំពុងចាត់ការបណ្ដឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្ដឹងនោះ។ ប៉ុន្តែនៅក្នុងករណីដែលកូនបានទទួលមរណភាពវិញ ក្រោយពីបានដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្ដឹងនោះ អំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព នេះបើក្នុងករណីកូនដែលទទួលមរណភាព មានបច្ឆាញាតិ។

ចំពោះការទទួលស្គាល់បិតុភាពដោយបុគ្គលជាកូនវិញ គឺកូនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបុគ្គលដែលជាឪពុកទទួលស្គាល់ខ្លួនបានក្នុងរយៈពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីដឹងថាជាឪពុក ប៉ុន្តែប្រសិនបើបុគ្គលជាកូនជានីតិជនហើយបានបដិសេធការទទួលស្គាល់របស់បុគ្គលដែលជាឪពុកពីមុនមកហើយនោះ មិនអាចដាក់បណ្ដឹងសុំទាមទារបានទេ។ ក្នុងករណីដែលកូន ឬបច្ឆាញាតិ ជាអនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុកអំឡុងពេល ១ (មួយ) ឆ្នាំ ត្រូវគិតចាប់ពីពេលដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះបានក្លាយជានីតិជន ឬពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ។ ការធ្វើបណ្ដឹងទាមទារនេះអាចធ្វើបានដែរ ក្រោយពេលការស្លាប់របស់បុគ្គល ដែលជាឪពុកដោយកូន ឬបច្ឆាញាតិផ្ទាល់ ឬអ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃមរណ-

ភាពរបស់បុគ្គលដែលជាឪពុក។ នៅក្នុងស្ថានភាពជាក់ស្តែង ភាគច្រើនម្តាយជាអ្នកដាក់ពាក្យប្តឹង នៅពេលដែលកូនជាអនីតិជននៅឡើយ។

បើបុគ្គលណាម្នាក់បានសុំចុះសំបុត្រកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថាបានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះសំបុត្រកំណើត។ ក្នុងករណីនេះពុំចាំបាច់មានការទទួលស្គាល់ថ្មី ឬជូនដំណឹងជាថ្មីម្តងទៀតទេ។[23]

## ផ្នែកទី៣៖ បណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាពនៃបុត្តភាព

### កថាខណ្ឌទី១ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ស្ត្រី គឺជាអ្នកដែលពពោះ ផ្តល់កំណើតឱ្យកូន ជាអ្នកសម្រាលកូនចេញពីផ្ទៃ។ បច្ចុប្បន្ន ក៏មានករណីមួយចំនួនដែលម្តាយបង្កើតកូនហើយបោះបង់គ្នាចោល។ ប៉ុន្តែទោះជាពេលខ្លះ ស្ត្រីខ្លះចិញ្ចឹមកូនទាំងដែរខ្លួនគាត់មិនមែនជាអ្នកផ្តល់កំណើតឱ្យកូនក៏ដោយ ក៏មាតុភាពរបស់កូននោះមិនត្រូវបានបង្កើតឡើងដែរ។ មាតុភាពអាចកើតបាន លុះត្រាតែកូនបានចេញពីផ្ទៃរបស់ម្តាយ តែមិនមែនអ្នកមិនមែនជាម្តាយ គឺអាចបញ្ជាក់អត្ថិភាពនៃ មាតុភាពរវាងកូនបានទេ។ កាលណាបើកូននោះអាចរកឃើញម្តាយបង្កើតរបស់ខ្លួន កូននោះអាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាពនៃមាតុភាព។

#### ១. បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន

ចំពោះកូនដែលត្រូវបានម្តាយបោះបង់ចោលតាំងពីនៅតូច ឬមូលហេតុណាមួយដែលធ្វើឱ្យកូនមិនស្គាល់ម្តាយ ហើយក្រោយមកបានដឹងអំពីអត្តសញ្ញាណរបស់ស្ត្រីដែលបានសម្រាលខ្លួន កូនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពចំពោះស្ត្រី ដែលបានបង្កើតខ្លួនបាន ហើយបើទោះបីជាកូនបានទទួលមរណភាពក៏ដោយ ក៏បច្ឆាញាតិផ្ទាល់របស់កូន អាចធ្វើការដាក់ពាក្យបណ្តឹងនេះបានដែរ។

យោងតាមកថាខណ្ឌទី១ មាត្រា ១០០៤ បានចែងថា កូនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន។ ហើយអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬបច្ឆាញាតិផ្ទាល់កូន អាចដាក់ពាក្យជំនួសបាន។ ប្រសិនបើកូនបានទទួលមរណភាព តែកូនមានបច្ឆាញាតិផ្ទាល់របស់ខ្លួននោះ បច្ឆាញាតិនោះអាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីជាម្តាយរបស់ឪពុកដែលត្រូវជាកូនរបស់ស្ត្រីនោះ គឺអាចដាក់ពាក្យបណ្តឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីដឹងថាជាម្តាយ។ ជាមួយគ្នា បើសិនកូន ឬបច្ឆាញាតិរបស់កូនជាអនីតិជន ឬជាជនស្ថិតនៅក្រោមអាណាព្យាបាល ត្រូវគណនាដោយគិតចាប់ពីពេលដែលកូន ឬបច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬត្រូវបានលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទទូទៅ នៅពេលដែលដឹងថាជាម្តាយ។

[23] សិក្ខាសាលាស្តីពី ទំនាក់ទំនងឪពុកម្តាយ និងកូន រួមទាំងកូនសុំកូន, ក្រុមការងារគណៈមេធាវី, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។

## ២. បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្តាយ

ចំពោះម្តាយក៏អាចដាក់បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃ មាតុភាពចំពោះកូនបានដែរ តែប្រសិនបើកូនបានទទួលមរណភាព ពាក្យបណ្តឹងនេះអាចធ្វើទៅបានទាល់តែកូនមាន បច្ឆាញាតិផ្ទាល់។ មួយវិញទៀត ប្រសិនបើកូន ឬបច្ឆាញាតិផ្ទាល់ ជានីតិជន ម្តាយត្រូវមានការយល់ព្រមពីកូន ឬបច្ឆាញាតិផ្ទាល់ នោះជាមុនសិនទើបអាចដាក់ពាក្យបណ្តឹងនេះបាន។ នៅពេលដែលបានដឹងថាជាកូនរបស់ខ្លួនម្តាយត្រូវដាក់ពាក្យបណ្តឹង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ បើទើបតែដឹងថាជាកូនក្រោយកូនទទួលមរណភាព គឺម្តាយអាចដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ។

ប្រសិនបើម្តាយជាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេល ១ (មួយ) ឆ្នាំបានកន្លងផុតរយៈពេល ត្រូវគណនាគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមនៅក្រោមអាណាព្យាបាលទូទៅ។ ទោះជាយ៉ាងណា បើការដាក់ពាក្យបណ្តឹងទាមទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីម្តាយ តែបើផ្ទុយនឹងផលប្រយោជន៍របស់កូន ឬបច្ឆាញាតិរបស់កូន នោះតុលាការអាចលើកចោលបណ្តឹងរបស់ម្តាយបាន។

អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព គឺមានតាំងពីពេលកំណើតរបស់កូននោះ មានន័យថា ម្តាយមានសិទ្ធិដើម្បីទទួលស្គាល់ និងបញ្ជាក់ពីអត្ថិភាពរបស់ខ្លួនចំពោះកូន តាំងពីមានកំណើតកូនមកម្លេះ។ បើទោះជាម្តាយអាចធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្តាយ ក៏ហេតុនេះមិនអាចបំពានសិទ្ធិរបស់តតិយជន ដែលបានធ្វើលទ្ធកម្មរួចមកហើយ។ តតិយជន គាត់អាចទាមទារនូវសំណងវិញនូវសេចក្តីចម្រើនឥតហេតុ ដែលបានកើតឡើងដោយមានការផ្គត់ផ្គង់ ចិញ្ចឹមមើលថែកូន ពីស្ត្រីជាម្តាយបង្កើត។

## កថាខណ្ឌទី២ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព គឺជានីតិវិធីមួយក្នុងការទាមទារទៅតុលាការឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ក្នុងករណីដែលបិតុភាព ឬមាតុភាពត្រូវបានបង្កើតឡើងដោយផ្ទុយនឹងការពិតជាក់ស្តែង។ ក្នុងការធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាពនៃបុត្តភាពអាចធ្វើឡើងតាមរយៈដូចខាងក្រោម[24]៖

- កូនអាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាព ឬមាតុភាពចំពោះជន ដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើតដោយមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬជន ដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះបីជាគ្មានហេតុដែលបានសម្រាលក៏ដោយ។ មានន័យថា ជនដែលជាកូន អាចធ្វើការស្នើសុំទាមទារឱ្យបញ្ជាក់ពីនត្ថិភាពនៃបុត្តភាព ពីបុគ្គលដែលមាននាមជាត្រឹមជា

---

[24] មាត្រា ១០០២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៦៧។

ម្ដាយ ឬមាននាមត្រឹមជាឪពុកនៅក្នុងសៀវភៅកំណើតតែប៉ុណ្ណោះ តែការពិតពួកគាត់មិនមែនជាឪពុកបង្កើត ឬម្ដាយបង្កើតទេ។

- អ្នកដែលជាឪពុក គឺជាជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថា ជាឪពុក ក៏ដោយអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន (មាត្រា ១០០២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ប្រសិនបើមានករណីឪពុកដែលនៅក្នុងសៀវភៅកំណើតកូនមានការទទួលកូន ដោយខ្លួនមិនមែនជាឪពុកបង្កើតរបស់កូន ដូច្នេះគាត់អាចធ្វើការប្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន នោះការទទួលស្គាល់នាកន្លងមក តម្រូវឱ្យចាត់ទុកជាមោឃៈ។
- បុគ្គលដែលជាម្ដាយ ក្នុងនាមជាម្ដាយតែនៅក្នុងសៀវភៅកំណើតរបស់កូន ដោយមិនមែនជាអ្នកសម្រាលកូននោះឡើយ គាត់អាចធ្វើបណ្ដឹងទាមទារឱ្យបញ្ជាក់ពីនត្ថិភាពនៃមាតុភាព។ ទោះជនដែលត្រូវបានចុះជាម្ដាយនៅក្នុងសៀវភៅកំណើត ហើយមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់នត្ថិភាពនៃមាតុភាពជាមួយកូនបាន (មាត្រា ១០០២ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។ បញ្ញត្តិនៅមាត្រា ១០០២ បានអនុញ្ញាតឱ្យម្ដាយដែលមិនមែនជាម្ដាយបង្កើត ដោយសារការបង្កើតឡើងដោយអង្គហេតុក្លែងក្លាយអំពីកំណើតកូន អាចមានសិទ្ធិទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាព។

បណ្ដឹងរបស់ឪពុក ឬម្ដាយដែលទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬមាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬកំហុសធ្ងន់ធ្ងររបស់ខ្លួន ដែលត្រូវ បានចុះជាឪពុក ឬម្ដាយនៅក្នុងសៀវភៅកំណើត ឬបើអំឡុងពេល ២០ ឆ្នាំបានកន្លងផុត គិតចាប់ពីថ្ងៃ កំណើតរបស់កូន ឬថ្ងៃដែលអានុភាពនៃការទទួលស្គាល់បានកើតឡើង (មាត្រា ១០០២ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី)។ ចំណុចនេះ កាលបើកូនបានដឹងថាខ្លួនមិនមែនជាកូនបង្កើតរបស់ឪពុក ឬម្ដាយដែលបានចុះក្នុងសៀវភៅកំណើត គឺវាធ្វើឱ្យមានការបំផ្លាញនូវការជឿទុកចិត្តរយៈពេលជាយូរមកហើយថា បិតុភាព ឬមាតុភាពក្លែងក្លាយនោះជាការពិត។

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ។ ប៉ុន្តែអានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយនោះឡើយ។ ក្នុងករណីនេះ បើសិនជាឪពុកមិនមែនជាឪពុកបង្កើតត្រូវបានចុះក្នុងសំបុត្រកំណើតថាជាឪពុក វាអាចត្រូវបានកែតម្រូវតាមរយៈបណ្ដឹងបដិសេធបិតុភាព ឬបណ្ដឹងទាមទារឱ្យបញ្ជាក់នត្ថិភាពនៃបុត្តភាព។ ប្រសិនបើឈ្មោះរបស់បុគ្គលដែលមិនមែនជាឪពុកត្រូវបានកត់ត្រាក្នុងសំបុត្រកំណើតដោយផ្អែកតាមការសន្មតនៃមាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណី

ឆ្នាំ ២០០៧ នោះបណ្តឹងបដិសេធបិតុភាពត្រូវបានយកមកប្រើ។ ផ្ទុយទៅវិញ ប្រសិនបើឈ្មោះរបស់បុគ្គលដែលមិនមែនជាឪពុកត្រូវកត់ត្រាក្នុងសំបុត្រកំណើត ដោយផ្អែកតាមការទទួល ស្គាល់ នោះបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្តិភាពនៃបុត្តភាពត្រូវបានយកមកប្រើ។[25]

[25] សិក្ខាសាលាស្តីពី ទំនាក់ទំនងឪពុកម្តាយ និងកូន រួមទាំងកូនសុំកូន, ក្រុមការងារគណៈមេធាវី, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។

# ជំពូកទី២
# អនុភាពនៃបុគ្គភាព

# ជំពូកទី២
# អានុភាពនៃបុត្តភាព

## ផ្នែកទី១៖ អំណាចមេបា

អំណាចមេបា គឺជាសិទ្ធិ និងករណីយកិច្ចដែលត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ ឪពុកម្តាយមានអំណាចមេបាទៅលើកូនក្នុងបន្ទុករបស់ខ្លួន។ ជាទូទៅឪពុកម្តាយមានមនោសញ្ចេតនា ចំពោះកូនអាណិតស្រឡាញ់កូន និងថ្នាក់ថ្នមកូនយ៉ាងយកចិត្តទុកដាក់បំផុត។ កូនត្រូវបានមានការទទួលថែរក្សា ចិញ្ចឹមបីបាច់ និងទទួលការអប់រំទូន្មាន ប្រៀនប្រដៅពីឪពុកម្តាយ ដើម្បីក្លាយជាកូនប្រកបដោយគន្លងធម៌។ លើសពីនេះ អ្នកដែលជាឪពុកម្តាយខិតខំតស៊ូនឹងការលំបាកគ្រប់យ៉ាងឱ្យតែកូនមានសុខភាពល្អ សុខសប្បាយ និងបានរៀនសូត្រ។ ឪពុកម្តាយគ្រប់រូបត្រូវការឱ្យកូនមានសុខភាពល្អចិត្តសប្បូរសប្បាយ និងមានសេចក្តីសុខ គ្មានឪពុកម្តាយណាម្នាក់ចង់ឱ្យកូនធំដឹងក្តីឡើងក្លាយជាមនុស្សញញើតញញើមប៉ុនខ្លាសអៀន ធ្វើអ្វីមិនចេះក្រែងចិត្តអ្នកដទៃ ឬជាក្មេងដែលមានបញ្ហា។ ប៉ុន្តែ តាមសង្គមជាក់ស្តែង ឪពុកម្តាយមួយចំនួនតូចបង្កើតកូនមកហើយ គឺពិតជាគ្មានទំនួលខុសត្រូវទាល់តែសោះចំពោះកូន មិនឱ្យកូនបានចូលរៀន នាំកូនដើរសុំទានគេ វាយដំកូន ប្រើប្រាស់កូនប្រៀបដូចជាអ្នកបម្រើ បោះបង់កូនចោល ទុកកូនចោលដូចក្មេងកំព្រា។

យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ក៏បានកំណត់អំពីអំណាចមេបា ដែលនិយាយអំពីករណីយកិច្ច ការទទួលខុសត្រូវ និងផ្តន្ទាទោសចំពោះអ្នកមានអំណាចមេបាដែលមានការបំពានទៅលើសិទ្ធិរបស់កូន។ នៅក្នុងផ្នែកទី១នេះ និយាយអំពីអំណាចនឹងបង្ហាញ ទំនាក់ទំនាងឪពុកម្តាយ និងកូនក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ និងទំនាក់ទំនងក្នុងករណីអនីតិសង្វាស។

### កថាខណ្ឌទី១ មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់

អាពាហ៍ពិពាហ៍តាមច្បាប់ គឺជាចំណងអាពាហ៍ពិពាហ៍មួយដែលអាចបង្កើតឱ្យមានករណីយកិច្ចរួមរស់នឹងគ្នា សហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមកក្នុងភាពជាអ្នកមានអំណាចមេបា។ អនុលោមតាមមាត្រា ១០៣៦ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧ បញ្ញត្តិអំពីគោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា ដែលចែងថា ឪពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ ប៉ុន្តែ បើឪពុក ឬម្តាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬម្តាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ។ ក្នុងន័យនេះ គេបានកំណត់យកតែអំណាចមេបាទោលតែប៉ុណ្ណោះ។ ឧបមាថា សហព័ទ្ធម្ខាងគាត់ត្រូវវិបល្លាស

វិកលចរិក ឬគ្មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងក្នុងនាមជាអ្នកមានអំណាចមេបា ដូច្នេះ ភាគីម្ខាងទៀតត្រូវប្រើអំណាចមេបានោះ។

### ១. ករណីឪពុកម្ដាយមិនលែងលះគ្នា

បន្ទាប់ពីអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងហើយ គូភាគីនៃអាពាហ៍ពិពាហ៍ក៏នឹងក្លាយទៅជាគូជីវិត ដែលតាមនិយមន័យច្បាប់ហៅថា សហព័ទ្ធ។ ដូច្នោះ ក្នុងឋានៈជាសហព័ទ្ធនេះបានផ្ដល់នូវសិទ្ធិនិងករណីយកិច្ចមួយចំនួន ទាំងក្នុងទិដ្ឋភាពទំនាក់ទំនងផ្ទាល់ខ្លួន និងទាំងក្នុងទិដ្ឋភាពទាក់ទងនឹងទ្រព្យសម្បត្តិ ព្រមទាំងទិដ្ឋភាពដែលពាក់ព័ន្ធនឹងកូនៗ។[26] នៅក្នុងក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិនៅក្នុងមាត្រាមួយចំនួន ដែលពាក់ព័ន្ធនឹងសិទ្ធ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបាចំពោះកូន ដោយតម្រូវឱ្យអ្នកដែលមានអំណាចមេបាគោរព និងអនុវត្តនូវករណីយកិច្ចមួយចំនួន នៅក្នុងអំឡុងពេលអនុវត្តជាអ្នកមានអំណាចមេបា។ ជាធម្មតាអ្នកដែលជាឪពុកម្ដាយ ត្រូវតែមើលថែរក្សាចិញ្ចឹមបីបាច់មើលថែរូបរាងកាយកូន ទាំងផ្លូវអារម្មណ៍របស់កូន បង្រៀនបង្ហាត់កូនឱ្យក្លាយជាមនុស្សល្អ សិស្សល្អ និងពលរដ្ឋល្អ។

ដោយយោងតាមមាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណីបានចែងថា អំណាចមេបា គឺសំដៅដល់អ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ ហេតុនេះបានន័យថា អំណាចមេបា គឺផ្ដើមចេញពីទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន ដែលឪពុកម្ដាយត្រូវសហការដោយព្រមព្រៀងបំពេញនូវករណីយកិច្ចចិញ្ចឹមបីបាច់ថែរក្សា និងគ្រប់គ្រងកូន។ ក្នុងករណីឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ ឪពុកម្ដាយត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាចំពោះកូនដែលជាអនីតិជន។ ចំណែកឯករណីដែល ឪពុក ឬម្ដាយ មិនអាចប្រើប្រាស់អំណាចមេបាដោយសហការគ្នាបានដោយសារតែឪពុក ឬក៏ម្ដាយ បាត់បង់សតិ បាត់ខ្លួន ឬមិនអាចទាក់ទងបានទេនោះ ឪពុក ឬម្ដាយ តែម្ខាងទៀតអាចប្រើប្រាស់អំណាចមេបានោះបាន។

ករណីយកិច្ចទាក់ទងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនរហូតដល់កូនមាននីតិភាព គឺជាតួនាទីរបស់អ្នកអំណាចមេបា។ ទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនក៏ដោយ ក៏សិទ្ធិអំណាចនៃការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនត្រូវបានកម្រិតដោយច្បាប់។ ហេតុដូច្នេះ អ្នកដែលមានអំណាចមេបា ត្រូវគោរពតាមករណីយកិច្ចដែលច្បាប់បានកំណត់ និងអនុវត្តនូវសិទ្ធិដែលខ្លួនមានក្នុងអំឡុងពេលជាអ្នកមានអំណាចមេបាចំពោះកូនឱ្យបានត្រឹមត្រូវ។[27]

[26] លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,ទំព័រទី ៣៤៧, បោះពុម្ពផ្សាយឆ្នាំ ២០១៧។

[27] លោកស្រី នូ ច័ន្ទសុគន្ធា, សៀវភៅអ្នកមានអំណាចមេបា, ទំព័រទី ១៣, ឆ្នាំ២០១៥។

## ២. ករណីលែងលះ

ការលែងលះជាមធ្យោបាយមួយនាំឱ្យចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយត្រូវបញ្ចប់ ហើយក៏នាំឱ្យសហព័ទ្ធនោះ និងញាតិរបស់សហព័ទ្ធនោះ លែងជាញាតិរបស់សហព័ទ្ធម្ខាងទៀតផងដែរ។ នៅពេលដែលលែងលះគ្នា អានុភាពដែលកើតដំបូង គឺការរំលាយនូវចំណងអាពាហ៍ពិពាហ៍ នាំឱ្យទំនាក់ទំនងញាតិដែលកើតឡើងដោយសារអាពាហ៍ពិពាហ៍ត្រូវបញ្ចប់។ ពាក់ព័ន្ធជាមួយនឹងទ្រព្យសម្បត្តិ និងបំណុល ត្រូវបែងចែកដោយយុត្តិធម៌ ដោយផ្អែកនៅលើការពិភាក្សារបស់ភាគីទាំងពីរ និងប្រសិនបើមិនអាចពិភាក្សាគ្នាបាននោះទេ សហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនទ្រព្យរួម មួយភាគពីរ នឹងបំណុលត្រូវសមាមាត្រគ្នា និងលើកលែងតែ មានករណីពិសេស ដែលអាចបញ្ជាក់ថាបំណុលនោះកើតឡើង មិនបម្រើឱ្យជីវភាពគ្រួសារ ជាអាទិ៍។ ហើយគេហកិច្ចត្រូវចាត់ទុកថាមានតម្លៃដូចការងារក្រៅផ្ទះ។ ត្រូវកំណត់អ្នកមានអំណាចមេបា ប្រសិនបើនៅក្នុងចំណងអាពាហ៍ពិពាហ៍មានកូន ថាតើកូននោះស្ថិតនៅក្រោមអំណាចមេបាររបស់សហព័ទ្ធខាងណា។ ប្ដីប្រពន្ធដែលបានផ្លាស់ប្ដូរនាមត្រកូលនៅពេលមានចំណងអាពាហ៍ពិពាហ៍ អាចផ្លាស់ប្ដូរនាមត្រកូលនោះវិញបាន។

ប្រសិនបើតុលាការចេញសាលក្រម ឬសាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។ ក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬបង់ប្រាក់ ឬផ្ដល់តាវកាលិកផ្សេងទៀត ក្នុងសាលក្រម ឬសាលដីកានោះបាន។[28] តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។[29]

នៅពេលដែលតុលាការធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះគ្នា នោះត្រូវយកយោបល់របស់កូនទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន។

ម្យ៉ាងវិញទៀត ប្រសិនបើមានការលែងលះតាំងពីកូនមិនទាន់កើតនៅឡើយ ម្ដាយគឺជាអ្នកមានអំណាចមេបាលើកូនដែលបានកើតនោះ។ ក៏ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាលើកូនបាន តាមរយៈការពិភាក្សារវាងឪពុកម្ដាយ។ ផ្ទុយទៅវិញ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ

---

[28] មាត្រា ២២ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃច្បាប់ស្ដីពី នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។

[29] មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

តុលាការជាអ្នកសម្រេច នៅពេលដែលមានពាក្យសុំរបស់ឪពុក ដោយផ្អែកតាមច្បាប់ស្តីពី នីតិវិធីនៃរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង។[30]

នៅក្នុងករណី បើមានការពិភាក្សារវាងភាគីសហព័ទ្ធទាំងសងខាង ឬមិនមានការសម្រុះសម្រួលរវាងគ្នា តុលាការអាចធ្វើការកំណត់ឱ្យភាគីណាម្ខាងដែលពុំមានអំណាចមេបា (ចំណុចនេះនឹងលម្អិតនៅក្នុងផ្នែកទី២ កថាខណ្ឌទី២ នៃជំពូកនេះ) គាត់មានសិទ្ធិចូលចួប និងប្រាស្រ័យទាក់ទងកូន ហើយក៏មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីមើលថែរក្សាកូន (ចំណុចនេះនឹងលម្អិតនៅក្នុងផ្នែកទី៣ កថាខណ្ឌទី១ ចំណុចទី៣ នៃជំពូកនេះ)។ តុលាការក៏ត្រូវធ្វើការពិចារណាកំណត់អំពីស្ថានភាពជីវភាព និងបញ្ហាសេដ្ឋកិច្ចរបស់អ្នកជាឪពុកម្តាយផងដែរ។ ក្នុងករណីនេះដែរ តុលាការក៏ត្រូវពិចារណាទៅតាមយោបល់ ឱ្យសមស្របតាមយោបល់របស់កូនផងដែរ។

តែទោះបីជាយ៉ាងណា ករណីលើកលែងនឹងមាន នៅក្នុងមូលហេតុនៃការលែងលះក៏ដោយក៏តុលាការអាចប្រានចោលការទាមទារលែងលះគ្នាបាន បើសិនការលែងលះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់គូភាគីនៃសហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬបើការលែងលះនឹងបណ្តាលឱ្យមានការឈឺចាប់មិនអាចទ្រាំទ្របាន (មាត្រា ៩៧៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

## កថាខណ្ឌទី២ ករណីអនីតិសង្វាស

អនីតិសង្វាស គឺជាស្ថានភាពរបស់បុរស និងនារី ដែលបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធដោយពុំបានចុះសំបុត្រអាពិហ៍ពិពាហ៍ ហើយរួមរស់ដោយឥតខានស្លា។ ការរួមរស់នៅជាមួយគ្នា ដោយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ គេហៅថា អនីតិសង្វាស។ បើមើលពីរូបភាពខាងក្រៅនៃទំនាក់ទំនងប្តីប្រពន្ធក្នុងស្ថានភាពនេះ វាពុំមានលក្ខណៈខុសគ្នាពីការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធស្របច្បាប់នោះទេ គ្រាន់តែការរួមរស់នៅជាមួយគ្នានោះមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យស្របនឹងច្បាប់។ ហេតុនេះ អាចនាំឱ្យប្តីប្រពន្ធនោះបាត់បង់នូវសិទ្ធិ ឬផលប្រយោជន៍មួយចំនួននៅក្នុងចំណងអាពាហ៍ពិពាហ៍អនីសង្វាស។

ដោយហេតុថា ឪពុកម្តាយដែលរស់នៅជាអនីតិសង្វាសមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដូច្នេះការផ្តាច់អនីតិសង្វាសរវាងឪពុកម្តាយ មិនទាមទារឱ្យមានការលែងលះក៏ពិតមែន ក៏ប៉ុន្តែ ការសម្រេចអំពីអំណាចមេបាលើកូន គឺអនុលោមតាមបញ្ញត្តិនៃការលែងលះ ពីព្រោះការផ្តាច់អនីតិសង្វាសនេះបានធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពនៃការរស់នៅរបស់កូន។ ដូច្នេះ ក្រោយពីការរំលាយចំណងអនីតិសង្វាសភាគីអាចសុំឱ្យតុលាការកំណត់អំពីអ្នកមានអំណាចមេបាលើកូន ប្រសិនបើគ្មានការពិភាក្សា។[31]

[30] លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,ទំព័រទី ៣៩៦, បោះពុម្ពផ្សាយឆ្នាំ ២០១៧។

[31] លោកស្រី នូ ច័ន្ទសុគន្ធា, សៀវភៅអ្នកមានអំណាចមេបា, ទំព័រទី៧, ឆ្នាំ២០១៥។

ការដាក់ពាក្យបណ្ដឹងលែងលះ ចំពោះចំណងអាពាហ៍ពិពាហ៍ គឺប្រាកដជាតុលាការលើកបណ្ដឹងនេះចោល ពីព្រោះវាជាបណ្ដឹងដែលមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយមានចំណុចខ្វះខាត ដោយមិនអាចកែតម្រូវបាន។[32] ប៉ុន្តែក្នុងករណីនេះ គេអាចដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបាន។ ដោយឡែក ប្រសិនបើក្នុងពាក្យបណ្ដឹងសុំផ្ដាច់អនីតិសង្វាស ភាគីដើមចោទបានទាមទារឱ្យតុលាការសម្រេចកំណត់អ្នកមានអំណាចមេបានោះ តុលាការនឹងធ្វើការសម្រេចអំពីការទាមទារឱ្យកំណត់អ្នកមានអំណាចមេបា។

ក្នុងករណីអនីតិសង្វាស ក្រមរដ្ឋប្បវេណីទទួលស្គាល់អំណាចមេបាទោលតែប៉ុណ្ណោះ។ កាលបើប្ដីប្រពន្ធនីតិសង្វាសបានលែងលះគ្នា អ្នកមានអំណាចមេបាមុនកំណើតរបស់កូន គឺម្ដាយ តែនៅក្រោយកំណើតរបស់កូន គឺអាចកំណត់យកឪពុកបានតាមការពិភាក្សារវាងឪពុក និងម្ដាយ។ ក្នុងការពិភាក្សា បើពុំបានសម្រេចនោះទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។ ចំពោះករណីដែលស្ត្រីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ទេ តែបានផ្ដល់កំណើតឱ្យកូន អ្នកដែលមានអំណាចមេបា គឺជាម្ដាយ ព្រោះឪពុកមិនអាចអនុវត្តការសន្មតបិតុភាពបានឡើយ។ មួយវិញទៀត បើស្ត្រីមិនទាន់រៀបអាពាហ៍ពិពាហ៍ជាអនីតិជនបានផ្ដល់កំណើតកូន ការកំណត់អំណាចមេបាមិនអាចជាអនីតិជនបានឡើយ ពីព្រោះតែអនីតិជនជាជនដែលពុំមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាព។

## កថាខណ្ឌទី៣ ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា

### ១. ការព្យួរ ឬដកហូត

ការព្យួរ ឬដកហូតអំណាចមេបា គឺអាចព្យួរ ឬដកហូតបាន នៅពេលដែលបុគ្គលដែលជាឪពុកម្ដាយមានការបំពានករណីយកិច្ចក្នុងភាពជាអ្នកមានអំណាចមេបា។ កាលណា អ្នកមានអំណាចមេបាបានប្រើប្រាស់នូវអំណាចមេបា ដែលហួសកម្រិត ឬករណីច្បាប់បានហាម ឬបានធ្វើកូនទទួលរងនូវព្យសនកម្មផ្លូវចិត្តរបស់កូនយ៉ាងធ្ងន់ធ្ងរ គឺតុលាការអាចធ្វើការព្យួរ ឬដកហូតអំណាចមេបាបាន។

ក្រោយពីមានការសម្រេចសេចក្ដីពីតុលាការក្នុងការកំណត់អ្នកដែលមានអំណាចមេបា មិនមែនមានន័យថាអ្នកដែលមានសិទ្ធិអំណាចមេបារួចហើយនោះទេ ប្ដី ឬប្រពន្ធដែលជាអ្នកមានសិទ្ធិអំណាចមេបា មិនអាចអនុវត្តសិទ្ធិរបស់ខ្លួនតាមអំពើចិត្តនោះទេ មានន័យថាប្រសិនបើប្ដី ឬប្រពន្ធ ឬអ្នកដែលមានសិទ្ធិស្របច្បាប់ក្នុងការទាមទារសិទ្ធិអំណាចមេបា បានដឹងអំពីការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកដែលមានសិទ្ធិអំណាចមេបាទេនោះ គឺជនទាំងនោះអាចប្ដឹងឱ្យដកហូត ឬព្យួរអំណាចមេបាបាន។[33] ក្នុងករណីដែលអ្នកមានអំណាចមេបា បាន

[32] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

[33] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។

បំពានសិទ្ធិអំណាច ឬធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបាដូចជា ការប្រើអំពើហិង្សាដែលបណ្តាលឱ្យកូនដែលជា អនីតិជនមានរបួសធ្ងន់ធ្ងរ ឬក្នុងករណីធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់កូន នោះតុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់របស់កូន មេឃុំ ឬចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។[34]

ការដកហូត ឬការប្រកាសព្យួរអំណាចមេបា គឺជាការដកសិទ្ធិទាំងស្រុង ឬបណ្តោះអាសន្នក្នុងការគ្រប់គ្រងកូនដែលជាអនីតិជន ទៅតាមការស្នើសុំរបស់អ្នកដែលមានសិទ្ធិក្នុងការស្នើសុំ ប្រសិនបើអ្នកដែលមានអំណាចមេបា មិនបានបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកមានអំណាចមេបាន។ ហេតុដូចនេះហើយទើបច្បាប់បានកំណត់ថា ឪពុក ឬម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិថ្នាក់ទី ៤ របស់កូន មេឃុំ ចៅសង្កាត់ ឬនាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។ ប្រសិនបើមានការប្រកាសព្យួរ ឬការដកហូតអំណាចមេបា ហើយកូនធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬម្តាយដែលពុំមានអំណាចមេបា មកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ក្នុងករណីនេះដែរប្រសិនបើអ្នកដែលមានអំណាចមេបាទទួលមរណភាព ដូច្នេះចំណុចខាងលើក៏ត្រូវបានយកមកអនុវត្តផងដែរ។

សរុបមក ក្នុងករណីអ្នកដែលមានសិទ្ធិអំណាចមេបាមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនពេញលេញ នោះអាចប្រឈមនឹងត្រូវបានតុលាការប្រកាសព្យួរ ឬដកហូតអំណាចមេបាបាន។ ការដកហូត និងការព្យួរអំណាចមេបា គឺធ្វើឡើងក្នុងគោលបំណងដើម្បីធានាឱ្យកូនទទួលបាននូវសិទ្ធិពេញលេញឡើងវិញ ដែលបណ្តាលមកពីការធ្វេសប្រហែស ឬការបំពានករណីយកិច្ចរបស់អ្នកមានអំណាចមេបា។

### ២. ការលុបចោលការប្រកាសការព្យួរ ឬដកហូត

ក្រោយពីការប្រកាសព្យួរ ឬការដកហូតអំណាចមេបា ត្រូវបានបញ្ចប់ តុលាការអាចលុបចោលការប្រកាសព្យួរ ឬការដកហូតសិទ្ធិក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលទទួលបានការប្រកាសព្យួរ ឬការដកហូតអំណាចមេបា ឬញាតិ៤ថ្នាក់របស់ជននោះ។ ប៉ុន្តែករណីដែលកូនធ្លាក់ទៅក្នុងស្ថានភាពដែលគ្មានអ្នកមានអំណាចមេបា មានន័យថាកូនកំព្រាដែលគ្មានឪពុកម្តាយគ្រប់គ្រង នោះអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមស្វែងរកអ្នកគ្រប់គ្រងថ្មី សម្រាប់កូននោះ ដែលមិនមែនជាឪពុកម្តាយបង្កើត (អ្នកមានអំណាចមេបា) គឺតុលាការត្រូវធ្វើការជ្រើសរើសអាណាព្យាបាលសម្រាប់អនីតិជនតាម

[34] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ អំណាចមេបា, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០។

ឆន្ទានុសិទ្ធិរបស់កូន ឬតាមការស្នើសុំពីញាតិ ៤ថ្នាក់ របស់កូននោះ ឬមេឃុំ ចៅសង្កាត់ នៃលំនៅឋានរស់នៅចុងក្រោយបង្អស់ ឬនាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។[35]

### ៣. ការលាឈប់ធ្វើជាអ្នកមានអំណាចមេបា

ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា គឺជាយន្តការមួយដែលតាមរយៈនោះ តុលាការអនុញ្ញាតឱ្យអ្នកមានអំណាចមេបាទោល (ឪពុក ឬម្តាយ) លាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ឬអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន។[36] មូលហេតុ នៃការលាឈប់ធ្វើជាអ្នកមានអំណាចមេបា អាចដោយសារមូលហេតុជាប់ពន្ធនាគារ ឬសម្រាកនៅមន្ទីរពេទ្យរយៈពេលវែង ឬធ្វើដំណើរទៅក្រៅប្រទេសជាអាទិ៍តាមពាក្យស្នើសុំរបស់អ្នកមានអំណាចមេបា នោះតុលាការអាចអនុញ្ញាតឱ្យមានការលាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបា តាមពាក្យសុំរបស់អ្នកមានអំណាចមេបា។ ក្នុងករណីអ្នកធ្លាប់មានអំណាចមេបាចង់ធ្វើបដិទាននូវអំណាចមេបាវិញបាន គឺទាល់តែមានការអនុញ្ញាតពីតុលាការ។

# ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា

## កថាខណ្ឌទី១ សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន

### ១. ការចិញ្ចឹមថែរក្សាកូន

ការចិញ្ចឹមថែរក្សាកូន គឺពិតជាត្រូវការការយកចិត្តទុកដាក់ខ្លាំងណាស់ ដើម្បីឱ្យកូនក្លាយជាក្មេងល្អ។ ការប្រើពាក្យសម្តីរបស់ឪពុកម្តាយ ប្រៀបដូចជាកាំបិតកោរដែលអាចធ្វើឱ្យកូនមានរបួសធ្ងន់ធ្ងរខាងផ្លូវចិត្តគំនិត បើមិនមានការប្រយ័ត្នប្រយែងទេនោះ វានឹងអាចធ្វើកូនក្លាយជាមនុស្សខុសប្រក្រតី ឬខុសពីក្មេងទូទៅ។

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចអប់រំកូន ពោលគឺជំរុញការអភិវឌ្ឍខាងបញ្ញារបស់កូន និងផ្តល់ឱ្យកូនទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ជីវិតនៅក្នុងសង្គមរបស់ខ្លួន។ ការអប់រំអាចបែងចែកជា២ គឺការអប់រំនៅក្នុងផ្ទះ និងការអប់រំនៅក្នុងសាលាដែលជាមូលដ្ឋានក្នុងការអប់រំផ្នែកបញ្ញា លើសពីនេះឪពុក ឬម្តាយមិនត្រូវបានអនុញ្ញាតឱ្យប្រើអំពើហិង្សា ដោយហៅអំពើហិង្សានោះថាជា វិន័យ ការអប់រំ ឬផ្តល់នូវការអប់រំ ដែលមិនត្រឹមត្រូវសម្រាប់ការរីកលូតលាស់របស់កូន ក្រោមរូបភាពនៃការប្រើប្រាស់សិទ្ធិនេះឡើយ។ ប៉ុន្តែនៅពេលផ្តល់ការអប់រំដល់កូន គាត់អាចស្តីបន្ទោស ឬដាក់ទណ្ឌកម្មកូននៅក្នុងកម្រិតមួយដែលចាំបាច់សម្រាប់ការអប់រំនៅក្នុងផ្ទះតែប៉ុណ្ណោះ តែត្រូវធានាថាការដាក់ទណ្ឌកម្មនោះមិនធ្វើឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬផ្លូវកាយដល់កូនជាដាច់ខាត។

[35] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។
[36] លោកស្រី នូ ច័ន្ទសុគន្ធា, សៀវភៅអ្នកមានអំណាចមេបា, ទំព័រទី១១, ឆ្នាំ២០១៥។

ជាងនេះទៅទៀត អ្នកមានអំណាចមេបា មានករណីយកិច្ចឱ្យកូនចូលសាលាយ៉ាងតិចណាស់៩ឆ្នាំ មានន័យថាអ្នកមានអំណាចមេបាមិនត្រូវបានអនុញ្ញាតឱ្យហាមឃាត់កូនមិនឱ្យចូលរៀន ដោយពុំមានហេតុផលពិសេសជាក់លាក់ឡើយ។ ក្រៅតែពីការផ្តល់ការអប់រំ អ្នកដែលមានអំណាចមេបា ត្រូវមានទីសំណាក់សម្រាប់កូន ដែលមិនអាចកំណត់ទីតាំងសំណាក់របស់កូននៅទីកន្លែងដែលមិនសមរម្យនោះទេ មិនត្រឹមតែប៉ុណ្ណោះអ្នកមានអំណាចមេបា ត្រូវអនុញ្ញាតឱ្យកូនប្រកបវិជ្ជាជីវៈ និងអាជីវកម្ម ថ្វីត្បិតតែច្បាប់បានកំណត់អំពីការប្រកបវិជ្ជាជីវៈ និងអាជីវកម្ម ត្រូវមានការអនុញ្ញាតពីអ្នកដែលមានអំណាចមេបាក្តីក៏អ្នកដែលមានអំណាចមេបាត្រូវតែផ្តល់ការអនុញ្ញាតឱ្យកូនផងដែរ។ ដោយហេតុថាការដែលមិនអនុញ្ញាតឱ្យកូនបានប្រកបអាជីវកម្ម និងវិជ្ជាជីវៈក៏ចាត់ទុកជាការបំពានលើសិទ្ធិក្នុងការផ្តល់ការអនុញ្ញាត។[37]

### ២. ការទាមទារឱ្យប្រគល់កូន

អ្នកមានអំណាចមេបាអាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ ប្រគល់កូនបាន។ [38] មានន័យថា បើកូននោះត្រូវតតិយជនយកទៅគ្រប់គ្រង តាមរយៈកិច្ចសន្យា យកទៅចិញ្ចឹម ឬយកទៅធ្វើអ្វីផ្សេងក្រៅពីនេះដែលខុសច្បាប់ អ្នកមានអំណាចមេបាអាចទាមទារឱ្យតតិយជននោះប្រគល់កូនមកឱ្យខ្លួនវិញ។ អ្នកមានអំណាចមេបាអាចទាមទារសំណងពីតតិយជនបាន ដោយសារការរំលោភលើអំណាចមេបា។ ប៉ុន្តែបើអនីតិជននោះបង្ហាញឆន្ទៈថាចង់រស់នៅជាមួយតតិយជន ដោយមិនមានការចាប់បង្ខំ តែព្រមដោយស្ម័គ្រចិត្ត មិនមានអ្វីដែលខុសច្បាប់ទេ។ ហើយបើតតិយជននោះកំពុងការពារកូននោះពីស្ថានភាពចាំបាច់អ្វីមួយ គឺតតិយជននឹងរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់។

អ្នកមានអំណាចមេបាអាចទាមទារឱ្យឪពុក ឬម្តាយដែលពុំមានអំណាចមេបាប្រគល់កូន។ ករណីដែលឪពុកម្តាយបានលែងលះគ្នា ហើយឪពុក ឬម្តាយណាម្ខាងត្រូវបានកំណត់ជាអ្នកដែលមានអំណាចមេបា ប៉ុន្តែឪពុក ឬម្តាយម្ខាងទៀតមិនព្រមប្រគល់កូន ឬករណីដែលឪពុកម្តាយចិញ្ចឹមបានក្លាយទៅជាអ្នកមានអំណាចមេបា ប៉ុន្តែឪពុកម្តាយបង្កើតដែលមិនមានអំណាចមេបាមិនព្រមប្រគល់កូនឱ្យទៅឪពុកចិញ្ចឹមជាដើម។ ប្រសិនបើអនីតិជននោះបង្ហាញឆន្ទៈបន្តរស់នៅជាមួយឪពុក ឬម្តាយមិនមានអំណាចមេបាដោយឆន្ទៈរបស់ខ្លួនផ្ទាល់ ឆន្ទៈរបស់កូននោះមិនត្រូវបានអើពើទាំងស្រុងទេ ហេតុដូច្នេះអ្នកមានអំណាចមេបានិងឪពុកម្តាយបង្កើតដែលមិនមានអំណាចមេបា ត្រូវពិភាក្សាគ្នាដើម្បីដោះស្រាយបញ្ហានេះ។[39]

[37] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។

[38] មាត្រា ១០៤៧, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។ ។

[39] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។

### ៣. ការគ្រប់គ្រងទ្រព្យសម្បត្តិកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និងក្នុងការតំណាងឱ្យកូននោះចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ។ ប៉ុន្តែ បើសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ សកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួលការយល់ព្រមពីកូននោះ។[40] ជាធម្មតា អនីតិជនពុំមានទ្រព្យសម្បត្តិច្រើនទេ ប៉ុន្តែអនីតិជនទទួលបាននូវទ្រព្យសម្បត្តិតាមរយៈសន្តតិកម្ម ប្រទានកម្ម សំណងនៃការខូចខាត ឬប្រាក់ដែលបានមកពីការធានារ៉ាប់រងជាអាទិ៍។ អ្នកមានអំណាចមេបាអាចធ្វើសកម្មភាពគតិយុត្តដែលមិនត្រឹមតែរួមមានសកម្មភាពគ្រប់គ្រងទ្រព្យសម្បត្តិតែប៉ុណ្ណោះទេ គឺថែមទាំងមានសកម្មភាពថែរក្សានិងសកម្មភាពចាត់ចែងទ្រព្យសម្បត្តិផងដែរ។[41]

ក្នុងករណីអ្នកមានអំណាចមេបាធ្វើសកម្មភាពបំពានករណីនេះ តុលាការអាចព្យួរ ឬដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបានតាមផ្លូវតុលាការ ប៉ុន្តែក្នុងករណីការបំពាននេះត្រូវបានបញ្ចប់ តុលាការអាចលុបចោលការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ តាមការទាមទាររបស់សាមីជនដែលបានទទួលការព្យួរ ឬដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬញាតិ ៤ថ្នាក់ របស់ជននោះ។[42]

### ៤. ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់កូន

អំពើអនីត្យានុកូល ជាអំពើដែលបំពានខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដ៏ទៃដោយកំហុសចេតនា ឬអចេតនាដែលអំពើទាំងនោះសំដៅទៅលើអំពើដែលមានត្រូវនឹងចំនុចណាមួយដូចខាងក្រោម៖

- អំពើបំពានដោយព្យាករ ឬគិតទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកផលប្រយោជន៍ការកើតឡើងនៃលទ្ធផលនោះ។
- អំពើដែលជាអំពើតាមប្រក្រតីរបស់បុគ្គល ហើយបុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធស្មើគ្នានឹងអ្នកធ្វើអំពើនោះអាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះបីជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។[43]

[40] មាត្រា ១០៥៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
[41] មាត្រា ១០៥៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។
[42] លោកស្រី នូ ច័ន្ទសុគន្ធា, សៀវភៅអ្នកមានអំណាចមេបា, ទំព័រទី១៦, ឆ្នាំ២០១៥។
[43] មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

ប្រសិនបើកូន បានបង្កឱ្យមានអំពើអនីត្យានុកូល អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យ គឺសំដៅទៅលើអ្នកជាឪពុកម្តាយ ឬម្តាយ ឬឪពុក ឬអាណាព្យាបាល ឬហិតូបត្ថម្ភ (ហិតូបត្ថម្ភ គឺការគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី) បុគ្គលមានករណីយកិច្ចដែលច្បាប់បានកំណត់ក្នុងការត្រួតពិនិត្យ អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ឬមានវិបត្តិខាងស្មារតី ឬមូលហេតុផ្សេងៗទៀត ត្រូវសងនូវការខូចខាតរបស់អ្នកដ៏ទៃ ដោយអំពើបំពានរបស់អ្នកនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ។[44]

### ៥. ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូន ដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន។[45] ការផ្តល់ការអប់រំដល់កូន គឺត្រូវស្ថិតក្នុងកម្រិតមួយដែលចាំបាច់ ដោយមិនធ្វើឱ្យមានការប៉ះពាល់ផ្លូវចិត្ត ឬប្រើអំពើហិង្សាយ៉ាងធ្ងន់ធ្ងរនោះទេ។ ការដាក់ទណ្ឌកម្មដែលបណ្តាលឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬផ្លូវកាយរបស់កូន គឺមិនត្រូវបានអនុញ្ញាតឡើយ។ ក្នុងករណី ដែលអំពើរបស់អ្នកមានអំណាចមេបា ឬអ្នកមានអំណាច ឬអ្នកដែលជាអាណាព្យាបាល ដែលបានដកហូតសេរីភាពរបស់អនីតិជន ដោយរំលោភអំណាចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើអំពើនេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពសុវត្ថិភាព ផ្លូវកាយ ផ្លូវចិត្ត ការអប់រំរបស់អនីតិជននោះ។[46]

## កថាខណ្ឌទី២ សិទ្ធិ និងករណីយកិច្ចរបស់អ្នកពុំមានអំណាចមេបា

បុគ្គលដែលពុំមានអំណាចមេបា គឺសំដៅទៅលើឪពុក ឬម្តាយ ដែលតុលាការមិនបានកំណត់ឱ្យក្លាយជាអ្នកមានអំណាចមេបា គឺកំណត់យកនរណាម្នាក់ ដែលអាចជាភាគីណាម្នាក់នៃឪពុកម្តាយ។ បើនិយាយឱ្យងាយយល់ទៅ អាចនៅក្នុងករណីឪពុកម្តាយលែងលះ ហើយតុលាការកំណត់អំណាចមេបាទោលឱ្យក្លាយជាអ្នកមានអំណាចមេបា។ ឪពុក ឬម្តាយ ដែលទទួលបានសិទ្ធិគ្រប់គ្រងកូន នៅតែមានចំណងញាតិស្របច្បាប់ជាមួយកូន ជាឪពុក ឬជាម្តាយដដែល។ ការប្រគល់សិទ្ធិឱ្យឪពុកជាអ្នកគ្រប់គ្រងកូន មិនមែនមានន័យថាចំណងគតិយុត្តរវាងកូន និងម្តាយត្រូវកាត់ផ្តាច់នោះទេ ហើយការប្រគល់សិទ្ធិទៅឱ្យម្តាយគ្រប់គ្រងជាអ្នកគ្រប់គ្រងកូន ក៏មិនមែនមានន័យថា ចំណងគតិយុត្តជាឪពុកត្រូវកាត់ផ្តាច់នោះដែរ។ ឪពុក ឬម្តាយ ដែលមិនបានទទួលសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិចូលចួប និងប្រាស្រ័យទាក់ទងជាមួយនឹងកូន ហើយក្នុងពេលជាមួយគ្នា

[44] មាត្រា ៧៩៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
[45] មាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
[46] ផ្នែកទី៣ មាត្រា ៣៤៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ចុះនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

នៅតែមានករណីយកិច្ចចូលរួមទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន។ ចំណែកឯឪពុក ឬម្តាយ ដែលទទួលសិទ្ធិគ្រប់គ្រងកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ក្នុងការចូលចួប សួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយកូន។

របៀបនៃការចូលចួប ការប្រាស្រ័យទាក់ទងជាមួយកូន និងការចូលរួមចំណែក ក្នុងសោហ៊ុយចាំបាច់ក្នុងការគ្រប់គ្រងថែរក្សាកូន (អាហារកិច្ច) គឺត្រូវកំណត់ តាមរយៈការជជែកពិភាក្សាគ្នា រវាងឪពុក និងម្តាយ។ ប្រសិនបើឪពុកម្តាយមិនមានការព្រមព្រៀងគ្នាទេ គឺតុលាការជាអ្នកសម្រេច ដោយយកផលប្រយោជន៍កូនជាធំ ហើយនៅក្នុងការកំណត់អំពីអាហារកិច្ច តុលាការក៏ត្រូវគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយដែរ។

**ឧទាហរណ៍** ប្តីប្រពន្ធមានកូនពីរនាក់ ហើយត្រូវលែងលះគ្នា ហើយតុលាការបានសម្រេចឱ្យខាងម្តាយជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន។ ដូច្នេះមានន័យថា ម្តាយជាអ្នកមានអំណាចមេបាលើកូន។ ចំណែកឪពុកពុំមានអំណាចមេបាទេ តែប្រសិនបើឪពុកមានពាក្យសុំពីតុលាការ នោះតុលាការនឹងសម្រេចពីការចូលចួប និងប្រាស្រ័យទាក់ទងឪពុកនឹងកូន ដូចជា ឱ្យឪពុក ចូលចួបនិងទាក់ទងកូន ក្នុងមួយសប្តាហ៍ម្តងចាប់ពីម៉ោង ១៤ និង ០០នាទី រហូតដល់ម៉ោង ១៧ និង ០០នាទី នៅផ្ទះខាងអតីតភរិយា ឬឪពុកមានសិទ្ធិយកកូនទៅផ្ទះរបស់ខ្លួនដើម្បីស្នាក់នៅជារៀងរាល់ថ្ងៃសៅរ៍ និងនៅម៉ោង ១៧ និង ០០ នាទីល្ងាចថ្ងៃអាទិត្យ។

ផ្ទុយទៅវិញ បើសិនជាខាងម្តាយ ឬឪពុកដែលជាអ្នកមានអំណាចមេបាទោលដោយសារការលែងលះគ្នា ហើយអ្នកមានអំណាចមេបានោះបានធ្វើឱ្យខូចប្រយោជន៍របស់កូន ដូចជា បានប្រព្រឹត្តនូវអំណាចណាមួយដែលមិនសមជាអ្នកមានអំណាចមេបា ជាអាទិ៍ នោះញាតិណាម្នាក់របស់កូនអាចទាមទារឱ្យតុលាការធ្វើការផ្លាស់ប្តូរអ្នកមានអំណាចមេបាបាន។

ចំណុចសំខាន់មួយទៀត ឪពុក ឬម្តាយ ដែលមិនទទួលបានសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀត រាយការណ៍អំពីស្ថានភាពរបស់កូននេះបាន។ ម្យ៉ាងទៀត ចំពោះកិច្ចការសំខាន់ៗ ដែលទាក់ទងនឹងអាយុជីវិតកូន ទាក់ទងនឹងអនាគតកូន ឪពុក ឬម្តាយ ដែលទទួលសិទ្ធិគ្រប់គ្រងកូន មានកាតព្វកិច្ចពិភាក្សាជាមួយនឹងភាគីម្ខាងទៀត មុននឹងធ្វើការសម្រេចអ្វីមួយ លើកលែងតែក្នុងករណីចាំបាច់បន្ទាន់ មិនអាចពិភាក្សាគ្នាបាន។

## ផ្នែកទី៣៖ អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច គឺជាកិច្ចដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមាន

ទំនាក់ទំនងញាតិនឹងគ្នា។[47] អាហារកាតព្វកិច្ច គឺមានបីប្រភេទដូចជា អាហារកាតព្វកិច្ចរវាងសហព័ទ្ធ អាហារកាតព្វកិច្ចរវាងញាតិ និងអាហារកាតព្វកិច្ចរវាងឪពុកម្តាយ និងកូនជាអនីតិជន។ ប៉ុន្តែនៅក្នុងប្រធានបទនេះនឹងលើកឡើងតែអំពីអាហារកាតព្វកិច្ចរវាងឪពុកម្តាយ និងកូនជាអនីតិជនតែប៉ុណ្ណោះ។

## កថាខណ្ឌទី១ អាហារកាតព្វកិច្ច និងអាហារកិច្ច

អ្នកជាមាតាបិតាមានកាតព្វកិច្ចថែរក្សា និងអប់រំកូនឱ្យទៅក្លាយជាពលរដ្ឋល្អ។[48] ពោល គឺឪពុកម្តាយមានករណីយកិច្ចត្រូវស្រឡាញ់កូន ចិញ្ចឹមបីបាច់រក្សាកូន និងយកចិត្តទុកដាក់អប់រំកូន គឺបណ្តុះបណ្តាលកូនឱ្យស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតី សាមគ្គីអន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។[49] អាហារកាតពព្វកិច្ចរវាងឪពុកម្តាយ និងកូនជាអនីតិជន ត្រូវបានកើតឡើងតាមរយៈអានុភាពនៃអំណាចមេបា ក្នុងនោះអ្នកដែលមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ច ត្រូវចិញ្ចឹមបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[50]

អាហារកាតព្វកិច្ចរវាងឪពុក ម្តាយ ចំពោះ កូនជាអនីតិជន គឺជាអាហារកាតព្វកិច្ចមួយក្នុងចំណោមអាហារកាតព្វកិច្ចទាំងបី ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ហើយវានឹងកើតឡើងនៅក្រោយពេលរំលាយអាពាហ៍ពិពាហ៍ តាមការព្រមព្រៀងរវាងភាគី ឪពុក ម្តាយ របស់របស់អនីតិជន ឬតាមសេចក្តីសម្រេចរបស់តុលាការ។ នៅពេលសាលក្រមលែងលះចូលជាស្ថាពរ ចំណងអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរំលាយ ចំណងគតិយុត្តរវាងភាគីទាំងពីរ ដែលមានរវាងគ្នានឹងគ្នាដូចពេលមានចំណងអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរំលាយ ចំណងគតិយុត្តរវាងភាគីទាំងពីរ ដេលមានរវាងគ្នានឹងគ្នា ដូចពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។

### ១.បុគ្គលផ្តត់ផ្គង់អាហារកាតព្វកិច្ច (អ្នកមានអំណាចមេបា)

ជនដែលមានកាតព្វកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះកូនជាអនីតិជនរបស់ខ្លួន គឺត្រូវស្របនឹងការរស់នៅនូវក្នុងកម្រិតដូចគ្នានឹងជីវភាព និងឋានៈក្នុងសង្គមរបស់ខ្លួន និងរក្សាកម្រិតនៃការរស់នៅរបស់ខ្លួនឱ្យសមរម្យទៅតាមលទ្ធភាពទ្រព្យធន។ តុលាការមិនគួរចេញសេចក្តីសម្រេច ដែលបង្គាប់ឱ្យជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចណា ដែលធ្វើឱ្យមានការពិបាកដល់ជីវភាពរបស់ជន ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឡើយ។ មានន័យថា បើបុគ្គលដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានជីវភាពខ្វះខាត ខ្វះនូវទ្រព្យធន ដើម្បីផ្តល់ទៅឱ្យកូន គឺតុលាការគួរពិចារណាទៅទំហំនៃលទ្ធភាពរបស់បុគ្គលផ្គត់

[47] សន្ធានុក្រមច្បាប់នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ១៧ ធ្នូ ២០០៩, លេខរៀងទី២០២។

[48] មាត្រា ៤៧, កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

[49] មាត្រា ១១៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យលេខ ៥៦, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩។

[50] មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

ផ្តង់អាហារកាតព្វកិច្ច។ របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច ជាគោលការណ៍ គឺជាការផ្តល់តាវកាលិកនូវប្រាក់ ពីជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច។ ជាការពិតណាស់ ប្រសិនបើអាចដោះស្រាយភាពចាំបាច់នៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមការផ្តល់តាវកាលិកនូវវត្ថុក្រៅពីប្រាក់ ការផ្តល់តាវកាលិកនូវវត្ថុនោះក៏អាចធ្វើទៅបានបន្ទាប់ពីការពិភាក្សារវាងភាគី ឬតាមការសម្រេចរបស់តុលាការ។[51]

ម្យ៉ាងទៀត ប្រសិនជាជនមានសិទ្ធិទទួលអាហារកិច្ចមានច្រើននាក់ ហើយលទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចពុំគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ចំពោះជនទាំងនោះទេ នោះពួកគេត្រូវការធ្វើការពិភាក្សា ដើម្បីកំណត់អំពីចំណែកដែលត្រូវទទួលពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឱ្យបានជាក់លាក់។ ប៉ុន្តែបើការពិភាក្សានោះពុំបានសម្រេចទេ តុលាការត្រូវកំណត់ អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឱ្យបានជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយចិត្តរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គល ដែលជាភាគី និងស្ថានភាពផ្សេងទៀតទាំងអស់។

ការផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាកត្តាមួយដែលផ្តល់លទ្ធភាពក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងញាតិ និងមនោសញ្ចេតនារវាងឪពុកម្តាយ និងកូន ក្រោយពេលគ្រួសារបាក់បែកគ្នា។ ប្រជាជនខ្មែរតែងប្រកាន់ខ្ជាប់នូវការស្រឡាញ់រាប់អាន មេត្តា ករុណា កតញ្ញូ ការអភ័យ ប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅរវាងគ្នាទៅវិញទៅមក។

### ២.បុគ្គលដែលទទួលបានអាហារកិច្ច (កូន)

ជាធម្មតា ដើម្បីអាចទទួលបាននូវអាហារកិច្ច គឺទាមទារឱ្យមានការព្រមព្រៀង ដោយបង្ហាញឆន្ទៈរវាងជនដែលមានសិទ្ធិទទួលបានអាហារកិច្ច និងជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

បុគ្គលដែលត្រូវការអាហារកិច្ច គឺជាជនដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនបាន សូម្បីតែក្នុងកម្រិតទាបបំផុត ដែលក្នុងពាក្យច្បាប់ត្រូវបានហៅថា ជនដែលមានសិទ្ធិទទួលបានអាហារកិច្ច។ ឧទាហរណ៍ កូនជាអនីតិជនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរកចំណូល ដើម្បីចិញ្ចឹមខ្លួនឯង ដូចនេះកូននោះគឺត្រូវការជំនួយដើម្បីទ្រទ្រង់ជីវិត។ ក្នុងករណីនេះជនដែលមានសិទ្ធិទទួលបាននូវអាហារកិច្ច គឺជាកូនដែលជាអនីតិជនដែលមានសមត្ថភាពធ្វើសកម្មភាព និងការត្រិះរិះពិចារណាមិនគ្រប់គ្រាន់នៅឡើយ។

ការបង់អាហារកាតព្វកិច្ចចំពោះកូន អាចត្រូវបានធ្វើឡើងតាមរយៈការព្រមព្រៀង ឬតាមការសម្រេចពីតុលាការ។ ច្បាប់ពុំបានដាក់កំហិត លើការកំណត់ពីទំហំអាហារកាតព្វកិច្ច ដែលតម្រូវឱ្យបុគ្គលដែលជាប់

[51] មាត្រា ១១៤២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។

កាតព្វកិច្ច បង់ក្នុងទំហំប៉ុណ្ណានោះឡើយ។ មួយវិញទៀត ច្បាប់ក៏ពុំបានចែង ឬបញ្ញត្តិត្រង់ឃ្លា ឬមាត្រាណាមួយ អំពីការបង់ផ្តាច់តែម្តង ដើម្បីបញ្ចប់កាតព្វកិច្ចដូចគ្នា ពីព្រោះថា ការបង់ផ្តាច់បែបនេះធ្វើឱ្យមានការប៉ះពាល់ដល់ ផលប្រយោជន៍របស់កូនដែលជាអនីតិជន ក្នុងនាមជាអ្នកមានសិទ្ធិ។ តើអ្នកដឹងទេ ថាបើសិនជាច្បាប់បានចែង ឬបញ្ញតិអំពីការបង់ផ្តាច់វានឹងធ្វើឱ្យមានផលវិបាកដល់កូន នៅក្នុងអំឡុងពេលជាអនីតិជននៅឡើយ?បញ្ហាទាំង នេះវា ធ្វើឱ្យក្មេងបាត់បង់ប្រយោជន៍សម្រាប់ជីវភាពរស់នៅរបស់ពួកគេ ពួកគេប្រៀបដូចជាក្មេងកំព្រាគ្មានឪពុក ម្តាយ គ្មានអ្នកប្រៀបប្រដៅ ណែនាំ និងផ្តល់ក្តីស្រឡាញ់ដូចក្មេងឯទៀត។

## ៣. ការកំណត់សោហ៊ុយចំណាយ ចំពោះការផ្គត់ផ្គង់កូនជាអនីតិជន

ការកំណត់សោហ៊ុយចំណាយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន ចំពោះទំហំនៃសោហ៊ុយចំណាយនោះ មុនពេលចេញសាលក្រមតុលាការពិចារណាទៅលើចំណុចជាច្រើនដូចជា កម្រិតជីវភាពរបស់អ្នកគ្មានអំណាច មេបា ដែលជាអ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ច ថាតើបុគ្គលនោះ មានសមត្ថភាពប៉ុនណា ដើម្បីផ្តល់សោហ៊ុយឱ្យកូន ជាមធ្យមកម្រិតជីវភាពរបស់កូនដែលធ្លាប់មានកន្លងមក តម្រូវការចាំបាច់របស់កូនដូចជា តម្រូវការផ្នែកអប់រំ ឬ ម្ហូបអាហារជាដើម។ បើក្រឡេកមើលទៅការកំណត់ទំហំសោហ៊ុយចំណាយចាំបាច់ដើម្បីថែរក្សាកូននៅក្នុងក្រម រដ្ឋប្បវេណី គឺមិនបានកំណត់អំពីរបៀបគណនាអំពីសោហ៊ុយចំណាយថា តើគួរចំណាយក្នុងកម្រិតណាមួយ ដើម្បីឱ្យសមស្របនឹងការចំណាយជាក់ស្តែង ប៉ុន្តែក្នុងក្រមនោះក៏បានកំណត់សោហ៊ុយចាំបាច់ខ្លះៗដែរ។

ឪពុកម្តាយដែលលែងលះគ្នា គឺមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រង កូន។ ហេតុនេះហើយទើបបញ្ហាផ្សេងទៀតត្រូវបានកែប្រែ និងត្រូវផ្លាស់ប្តូរ នោះគឺវាទាក់ទងនឹងការបែងចែកទ្រព្យ សម្បត្តិ ការបែងចែកអំណាចមេបាទៅលើកូន ជាពិសេស គឺទាក់ទងនឹងសោហ៊ុយចំណាយចាំបាច់ដើម្បី គ្រប់គ្រងថែរក្សាកូន។

ប៉ុន្តែបើការពិភាក្សាអំពីសោហ៊ុយចំណាយនោះមិនអាចសម្រេច បាននោះតុលាការត្រូវកំណត់អំពី សោហ៊ុយចាំបាច់ជំនួសឪពុក ឬម្តាយដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទារឪពុក ឬ ម្តាយនោះ។ ករណីមួយ គឺតែងតែឃើញកើតឡើងក្នុងកំឡុងពេលផ្តល់ជាសោហ៊ុយចំណាយ ចាំបាច់ដើម្បីថែ រក្សាកូន នោះគឺឪពុក ឬម្តាយដែលពុំមានអំណាចមេបា ដែលមានតួនាទីផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ដើម្បី ថែរក្សាកូន គឺពុំបានបង់សោហ៊ុយចំណាយតាមការកំណត់ដូចមានកំណត់ក្នុងសាលក្រមស្ថាពររបស់តុលាការ ជាដើម។ បើទោះបីជាការកំណត់សោហ៊ុយចំណាយចាំបាច់ ក្រមរដ្ឋប្បវេណីមិនបានកំណត់ពីការគណនាចំនួន ជាក់លាក់ណាក៏ដោយ ប៉ុន្តែចំនួនសោហ៊ុយចំណាយចាំបាច់ នោះគឺបានកំណត់ទៅហើយតាមរយៈការពិភាក្សា គ្នារវាង ម្តាយ ឬតាមសេចក្តីសម្រេចរបស់តុលាករដោយមានការស្នើសុំពីឪពុកម្តាយរបស់អនីតិជននោះ បន្ទាប់ មកទៀតទើបតុលាការចេញសាលក្រមសម្រេចសេចក្តី។ ដូច្នេះ បើមានករណីដែលឪពុក ឬម្តាយដែលពុំមាន

អំណាចមេបាមិនបង់ប្រាក់សោហ៊ុយចំណាយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន នោះមានន័យថាបុគ្គលនោះមិនបានអនុវត្តកាតព្វកិច្ចតាមសាលក្រមរបស់តុលាការទេ។

ការមិនអនុវត្តកាតព្វកិច្ចតាមសេចក្តីសម្រេចរបស់តុលាការក្នុងចំណុចនេះ សំដៅទៅលើបុគ្គលដែលគ្មានអំណាចមេបា ដែលមានករណីយកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ដល់កូនជាអនីតិជនមិនបានបង់សោហ៊ុយនោះតាមពេលកំណត់ ឬពុំបានបង់សោហ៊ុយនោះតែម្តង។ ដូចនេះ ចំពោះជនដែលមានករណីយកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ត្រូវទទួលទណ្ឌកម្មដូចជា ការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំ ជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជន ដោយប្រើអំណាចរដ្ឋ។ នីតិវិធីការអនុវត្តដោយបង្ខំនេះ មានគោលបំណង ការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ។ ក្នុងករណី ដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬកូនបំណុល មិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃការទាមទារ ឬសិទ្ធិប្រាតិភោគ តាមរយៈការប្រើប្រាស់អំណាចអាជ្ញាធររបស់រដ្ឋ។

ភាគីដែលជាអ្នកមានអំណាចមេបា ឬកូនដែលជាអនីតិជន ដែលជាបុគ្គលមានសិទ្ធិទាមទារតាវកាលិកពីភាគីដែលមានកាតព្វកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សា ភាគីនោះអាចទាមទារឱ្យសម្រេចសិទ្ធិដោយការអនុវត្តដោយបង្ខំ។

ក្នុងករណីយឪពុកម្តាយបោះបង់គ្រួសារ ដោយមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការដោយមិនព្រមបង់ ពីរខែយ៉ាងតិច នូវអាហារកាតព្វកិច្ចដល់កូនជាអនីតិជន គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ (មួយ) សែន ដល់ ២ (ពីរ) លានរៀល។[52]

## កថាខណ្ឌទី២ ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច

ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច គឺធ្វើឡើងដោយផ្អែកទៅស្ថានភាពជាក់ស្តែងរបស់អ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ច ថាតើគាត់មានបុគ្គលិកលក្ខណៈយ៉ាងដូចម្តេច? មានជីវភាពធូរធារ ឬអត់? គាត់មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ផ្តល់អាហារកាតព្វកិច្ចទៅអ្នកមានសិទ្ធិទទួលបានអាហារកិច្ចដែរ ឬទេ? តើគាត់បានប្រព្រឹត្ត ឬបានធ្វើអ្វីដែលច្បាប់ហាមឃាត់ដែរ ឬទេ? ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច ធ្វើតាមរយៈការពិភាក្សា ឬតាមរយៈសេចក្តីសម្រេចរបស់តុលាការ។

[52] មាត្រា ៣២៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ប្រសិនបើមានការផ្លាស់ប្តូរស្ថានភាព ក្រោយពីបានពិភាក្សា ឬក្រោយពីមានការសម្រេចសេចក្តីចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬជនដែលទទួលអាហារកិច្ចជាក់លាក់ ឬកម្រិត ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចភាគីអាចផ្លាស់ប្តូរបាន មានន័យថា ទំនាក់ទំនងនៃអាហារកាតព្វកិច្ច អាចត្រូវបានលុបចោល ឬផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពនៃការពិភាក្សា និងប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យ តុលាការនឹងបង្គាប់ឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចមុន។[53]

សិទ្ធិរបស់ជនដែលមានសិទ្ធិទទួលអាហារកិច្ច ពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាកម្មសិទ្ធផ្តាច់មុខរបស់ជនដែលមានសិទ្ធិទទួលអាហារកិច្ច ហើយមិនអាចក្លាយទៅជាកម្មវត្ថុនៃការជួញដូរណាមួយឡើយ។ អាស្រ័យហេតុនេះ ជនដែលមានសិទ្ធិទទួលអាហារកិច្ចនោះ មិនត្រូវយកផលដែលទទួលបានពីជនផ្គត់ផ្គង់អាហារកាតព្វកិច្ច ដើម្បីខ្ចីប្រាក់ពីអ្នករកស៊ី ចងការប្រាក់ ដូចសិទ្ធិលើបំណុលដែលនោះបានទេ ហើយមិនគួរឱ្យមានហេតុការណ៍នេះ។[54]

[53] មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

[54] មាត្រា ១១៤៤ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ចំណងគតិយុត្តនៃបុត្តភាព គឺជាទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ដែលឆ្លុះបង្ហាញអំពីទំនួលខុសត្រូវរបស់អ្នកជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកមានសិទ្ធិគ្រប់គ្រងចំពោះកូន។

ជារួមមកការបង្កើតឱ្យបាននូវបុត្តភាព គឺតម្រូវឱ្យមានទំនាក់គតិយុត្តរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដើម្បីផ្សះផ្សារទំនាក់ទំនងជាគ្រួសារ។ បន្ទាប់ពីមានចំណងអាពាហ៍ពិពាហ៍នៅក្នុងគ្រួសារ ក្នុងនាមជាឪពុកម្តាយត្រូវតែមានទំនួលខុសចំពោះកូន តាំងពីចាប់កំណើតក្នុងផ្ទៃដោយមើលថែទាំគភ៌នៅក្នុងផ្ទៃ។ ពេលកូនកើតហើយ គឺត្រូវទៅចុះសំបុត្រកំណើតឱ្យកូន ដើម្បីឱ្យកូនទទួលបាននូវបុគ្គលភាពគតិយុត្ត។ ទោះជាយ៉ាងនេះក្តី ទំនាក់ទំនងគ្រួសារខ្លះ មិនមែនជាសាច់សែលោហិតនឹងគ្នាទេ ប៉ុន្តែដោយការចង់បាន ឬក្តីស្រឡាញ់ ទើបទាមទារឱ្យមានចំណងគតិយុត្តនឹងគ្នា ដូចជាមឪពុកម្តាយ និងកូនចិញ្ចឹមជាដើម។

ទន្ទឹមនឹងនេះ នៅក្នុងសង្គមសព្វថ្ងៃនេះ មានបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងបុត្តភាព បញ្ហាទាំងនេះកើតឡើង ដោយសារតែសង្គមមនុស្សមួយចំនួនតូចមិនបានផ្តល់តម្លៃនឹងយកចិត្តទុកដាក់ទៅលើទំនាក់ទំនងគ្រួសារឡើយនៅក្នុងជីវភាពរស់នៅ មនុស្សមួយចំនួនមិនបានយល់អំពីច្បាប់ មិនយល់ពីសម្ព័ន្ធមនោសញ្ចេតនា ទើបធ្វើឱ្យមានភាពរង្គោះរង្គើរខ្លះកើតឡើងបង្កជាវិវាទ មានការប្តឹងផ្តល់ ទាមទារផលប្រយោជន៍ ដោយមិនគិតពីប្រយោជន៍អ្នកទន់ខ្សោយ ហើយគ្មានទំនួលខុសត្រូវ ព្រោះចំណងអាពាហ៍ពិពាហ៍មានបញ្ហា ការអស់មនោសញ្ចេតនានឹងគ្នា ទំនាក់ទំនងឪពុកម្តាយចិញ្ចឹម មរតកសាសន៍ ការកំណត់អ្នកមានអំណាចមេបា ការគ្រប់គ្រងកូន ទ្រព្យសម្បត្តិកូន ទំនួលខុសត្រូវកូនចំពោះអំពើអនីត្យានុកូលជាដើម។ នេះជាមូលហេតុទាំងឡាយដែលប្រធានបទស្តីពី បុត្តភាព បានលើកយកចំណុចពាក់ព័ន្ធនឹងច្បាប់ បទដ្ឋានគតិយុត្តនានា ដោយបានចោទជាបញ្ហាពាក់ព័ន្ធនិងឆ្លុះបង្ហាញអំពីផលប្រយោជន៍កូន ផលប្រយោជន៍ឪពុកម្តាយ។ ដូចនេះ ទើបច្បាប់បានបញ្ញត្តិអំពីការសម្រេចបុត្តភាព បណ្តឹងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ដើម្បីការពារប្រយោជន៍កូន ឬឪពុកម្តាយ។

អំពីបុត្តភាពមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ជនទាំងឡាយ ដើម្បីឱ្យមានគ្រួសារមួយសមរម្យក្នុងសង្គម ប្រកបដោយមនោសញ្ចេតនាជ្រាលជ្រៅជាមួយសមាជិកគ្រួសារ ទទួលបាននូវសេចក្តីស្រឡាញ់ ទទួលបានភាពកកក្តៅ ទទួលបានអាហារកាតព្វកិច្ច ទទួលបាននូវការថែទាំ និងទទួលបានទំនាក់ទំនងដែលល្អក្នុងភាពជាមនុស្សជាតិនៃសង្គម។

អានុភាពនៃបុត្តភាពនឹងកើតនៅពេលដែលមានការកំណត់អ្នកមានអំណាចមេបា សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា និងអាហារកាតព្វកិច្ចដែលត្រូវបានកំណត់ឡើងដោយច្បាប់។ ក្នុងករណីនេះ វាបានបង្ហាញពីទំនួលខុសត្រូវរបស់អ្នកមានអំណាចមេបា ទៅដល់អ្នកដែលទទួលបានប្រយោជន៍នេះ។ ដោយឡែកច្បាប់ក៏បានផ្តល់នូវសិទ្ធិមួយចំនួនដល់អ្នកដែលពុំមានអំណាចមេបា ដើម្បីធ្វើការប្រាស្រ័យទាក់ទងកូន។ ប៉ុន្តែ

នៅក្នុងលក្ខខណ្ឌដែលប៉ះពាល់ប្រយោជន៍ទៅលើបុគ្គលណាម្នាក់វានឹងមានបញ្ហា ជាពិសេសគឺការប៉ះពាល់ប្រយោជន៍របស់កូន ឬប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់កូន។ មួយវិញទៀត បើអ្នកមានអំណាចមេបាបានប្រើសិទ្ធិអំណាចរបស់ខ្លួនបំពានទៅលើសិទ្ធិរបស់កូន ឬបំពានលើការកំណត់របស់ច្បាប់ដែលបានហាម នោះតុលាការនឹងធ្វើការព្យួរ ឬដកហូតអ្នកមានអំណាចមេបា ឬអាចឈានទៅដល់ការលុបចោលទៀតក៏មានដែរ។

# អនុសាសន៍

# អនុសាសន៍

មិនមានអ្វីដែលថាល្អឥតខ្ចោះនោះទេ ដូច្នេះគ្រប់គោលបំណង គ្រប់គោលដៅ និងបំណងប្រាថ្នាសុទ្ធតែមានការខ្វះចន្លោះ។ ការរស់នៅរបស់មនុស្សក្នុងសង្គម មានបញ្ហាជាច្រើនដែលវាតែងតែកើតឡើងជាញឹកញាប់ ទោះបញ្ហាខ្លះត្រូវបានច្បាប់បញ្ញត្តិតាក់តែងឡើងក៏ដោយ តែវាក៏មានចំណុចខ្លះដែលមិនទាន់គ្រប់គ្រាន់ នឹងអាចដោះស្រាយបាន។ ចំពោះអនុសាសន៍យើងខ្ញុំទាំងពីរសូមសំណូមពរដល់អ្នកនីតិករ និងក្រុមប្រឹក្សាអ្នកច្បាប់តាក់តែងច្បាប់ឡើងដែលពាក់ព័ន្ធនឹងបញ្ហាបច្ចុប្បន្ន។

យើងដឹងថា នៅកម្ពុជាបច្ចុប្បន្ន គឺមានអ្នកស្រឡាញ់ភេទដូចគ្នា អាចស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស។ ថ្វីដ្បិតតែ ឥរិយាបថបែបនេះវាបានប៉ះពាល់ដល់សង្គមក៏ពិតមែន មានន័យថា វាបានប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាតិសាសន៍ខ្មែរ ខុសលក្ខខណ្ឌធម្មជាតិដែលបុរសនិងស្រីគួរតែជាគូនឹងគ្នារួមរស់ជាមួយគ្នា ណាមួយសង្គមមួយចំនួនធំមិនអាចទទួលយកបានចំពោះការស្រឡាញ់ស្រីភេទដូចគ្នា។ ក្នុងករណីនេះ យើងមិនអាចហាមឃាត់បានទេ ហើយក៏គ្មានឃើញបញ្ញត្តិណាហាមឃាត់ឡើយ ទោះច្បាប់មិនបានកំណត់អ្នកស្រឡាញ់ភេទដូចគ្នា។ ដូចនេះ ជាមួយគ្នានេះ យើងខ្ញុំសូមសំណូមពរឱ្យនីតិករ និងក្រុមប្រឹក្សាអ្នកច្បាប់ និងស្ថាប័នពាក់ព័ន្ធបង្កើតតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងចំណុចនេះឡើងមក ដើម្បីងាយស្រួលដោះស្រាយបញ្ហាដែលនឹងអាចកើតឡើងនាពេលអនាគត ដែលមិនអាចមើលដឹងទុកជាមុន។

ដោយឡែក អ្វីដែលសំខាន់គួរតែផ្ដោតទៅលើច្បាប់ដែលស្ដីពី ការបង្កើតកូនតាមវេជ្ជសាស្ត្រ ព្រោះថាបច្ចុប្បន្ននេះក៏មានប្ដីប្រពន្ធខ្លះ គាត់ពិបាកបង្កើតកូន បញ្ហាសុខភាពមិនអាចមានកូនបាន ទើបធ្វើឱ្យវេជ្ជសាស្ត្រក្រុមពេទ្យជំនាញមានការបង្កើតកូនក្នុងកែវ ដោយប្រើមេជីវិតឈ្មោល និងមេជីវិតញីបញ្ចូលគ្នា ដើម្បីភ្ញាស់បង្កើតនូវកោសិកាកូន បន្ទាប់មកត្រូវយកទៅចិញ្ចឹមក្នុងកែវ។ មួយវិញទៀត ការឱ្យមានការពពោះជំនួស (ការស៊ីឈ្នួលពពោះ) ហើយនៅក្នុងក្រមរដ្ឋប្បវេណីពុំមានបញ្ញត្តិចែងពាក់ព័ន្ធឡើយ។ បើបែបនេះតទៅទៀត កម្ពុជានឹងប្រឈមនឹងការដោះស្រាយបញ្ហាទាក់ទងនឹងបុត្តភាព ដែលយើងអាចនឹងពិបាកធ្វើការសន្និតអំពីបិតុភាព ឬក៏ មាតុភាព។ ទោះវេជ្ជសាស្ត្រទំនើបប៉ុណ្ណាក៏ដោយ បើពុំមានច្បាប់បញ្ញត្តិចែងពាក់ព័ន្ធនឹងបញ្ហានេះទេ អ៊ីចឹងបញ្ហា នឹងបង្កើតឱ្យមានវិវាទកើតឡើងមិនចេះឈប់ឈរ។ ហើយវិបត្តិនេះ វាធ្វើឱ្យប៉ះពាល់ដល់ក្មេងៗដែលជាកូន ហើយនឹងមិនអាចទទួលបាននូវភាពកក់ក្ដៅ និងសេចក្ដីស្រឡាញ់ពីឪពុកម្ដាយពិតប្រាកដបានឡើយ។

យ៉ាងណាមិញ នៅក្នុងសង្គមខ្មែរមានច្រើនណាស់ក្មេងកំព្រា ក្មេងអនាថា ដែលដើរសុំទាន តាមផ្លូវសាធារណៈ ដែលយើងមើលទៅវាពិតជាអនាធិបតេយ្យ ក្មេងមួយចំនួនគ្មានជម្រកច្បាស់លាស់ គ្មានអ្នកមើលថែចុះនៅពេលពួកគេឈឺថ្កាត់តើនណាទទួលខុសត្រូវ។ អំពើរបស់ឪពុកម្ដាយមួយចំនួនពិតឃោឃៅ ដែលបង្កើតគ្នាហើយបំបោះបំបង់គ្នាចោល តើឱ្យគ្នាទៅពឹងនរណា? ដូច្នេះ យើងខ្ញុំក៏សំណូមពរឱ្យរាជរដ្ឋាភិបាល អង្គការក្រៅ

រាជរដ្ឋាភិបាល អ្នកច្បាប់ ជួយបង្កើតច្បាប់ដើម្បីការពារ និងផ្តល់សិទ្ធិ ហើយនឹងស្វែងរកជំនួយក្មេងៗទាំងនោះ ឱ្យបានចូលរៀន មានកន្លែងស្នាក់នៅសមរម្យ ដើម្បីបណ្តុះឱ្យក្លាយជាធនធានមនុស្សជួយកសាងសង្គម។ ទោះបីថាមានអង្គការមួយចំនួនបានជួយជ្រោមជ្រែងដល់ក្មេងមួយចំនួនក្តីក៏ដោយ ប៉ុន្តែវានៅតែមានកម្រិត និងមិនទាន់គ្រប់នៅឡើយ សម្រាប់ជួយដល់ក្មេងដទៃទៀតនៅក្នុងសង្គមជាក់ស្តែង។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញព្រះរាជណាចក្រកម្ពុជាចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ១២០៧/០៣០ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ (ចូលជាធរមានចាប់ពី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១)។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដាឆ្នាំ២០០៦។
- ក្រមរដ្ឋប្បវេណីព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៦៧។
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ក្រឹត្យលេខ ៥៦, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩។
- ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។
- ប្រកាសអន្តរក្រសួង លេខ ១៤៣៤២ ស្តីពីការផ្តល់ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦។

## ២.សៀវភៅ

- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, បោះពុម្ពផ្សាយឆ្នាំ ២០១៧។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។
- លោកស្រី នូ ច័ន្ទសុគន្ធា, សៀវភៅអ្នកមានអំណាចមេបា។
- សៀវភៅ តម្រង់ទិសវិជ្ជាជីវៈ «ឯកសារចំណេះដឹង អត្រានុកូលដ្ឋាន» របស់អង្គការស៊ីប៉ា។
- សិក្ខាសាលាស្តីពី ទំនាក់ទំនងឪពុកម្តាយ និងកូន រួមទាំងកូនស្មុំកូន, ក្រុមការងារគណៈមេធាវី, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤។

## ៣. គេហទំព័រ

- នាទីយល់ដឹងអំពីច្បាប់ និងជំនួញ, សេង ឌីណា, អំពីបែបបទនៃការសុំចុះសៀវភៅអត្រានុកូលដ្ឋាន

- កំណើត (សំបុត្រកំណើត), ចុះផ្សាយនៅថ្ងៃ៖ ២៨.០៣.២០១៣- ០៣:០០កែប្រែថ្ងៃទី ២៨.០៣.២០១៣ -១៣:៥៥។
- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។
- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២។
- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ អំណាចមេបា, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០២០។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះ | លេខឧបសម្ព័ន្ធ |
|---|---|---|
| ១ | ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ (ចូលជាធរមានចាប់ពី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១)។ | **ឧបសម្ព័ន្ធទី១** |
| ២ | អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។ | **ឧបសម្ព័ន្ធទី២** |
| ៣ | ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។ | **ឧបសម្ព័ន្ធទី៣** |

# ឧបសម្ព័ន្ធទី១

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ៤
## ឪពុកម្ដាយ និង កូន
### ផ្នែកទី ១
### បុត្តភាព
#### កថាភាគទី ១
#### បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៨៥.–** ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្ដាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្ដាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពី

ថ្ងៃដែលកូននោះកើត ។ ប្រសិនបើឪពុក ឬ ម្ដាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្ដាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះ ឱ្យបានឆាប់រហ័ស ។

២-ក្នុងករណីដែលឪពុកម្ដាយបានធ្វេសប្រហែសនឹងករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៩៨៦.–** វិធីគណនាអាយុ

១-អាយុត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ។

២-បញ្ញត្តិនៃមាត្រា ៣៣៥ (ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគណនាអាយុ ។

## កថាភាគទី ២
## ការសម្រេចអំពីបុត្តភាព

**មាត្រា ៩៨៧.–** មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន ។

**មាត្រា ៩៨៨.–** ការសន្និតបិតុភាព

១-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្និតថាជាកូនរបស់ប្ដី ។

២-កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្និតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

៣-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើត

កូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍-ពិពាហ៍ក្រោយ ។

**មាត្រា ៩៨៩.–** ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

**មាត្រា ៩៩០.–** បណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្ត ដោយបណ្ដឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៩៩១.–** បណ្ដឹងបដិសេធបិតុភាព ពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្ដឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្ដាយដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំមួយ)

ខែ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានកន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៩៩២.–** អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

## កថាភាគទី ៣
## ការទទួលស្គាល់

**មាត្រា ៩៩៣.–** ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

**មាត្រា ៩៩៤.–** សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ៩៩៥.–** ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្ដាយ ។

**មាត្រា ៩៩៦.–** ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព

១-ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់

បានឡើយ បើគ្មានការយល់ព្រមពីកូននោះ ។

២-ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៩៧ (ទម្រង់នៃការទទួលស្គាល់) ខាងក្រោមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

**មាត្រា ៩៩៧.–** ទម្រង់នៃការទទួលស្គាល់

១-ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ ។

២-ការយល់ព្រមរបស់ម្ដាយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

**មាត្រា ៩៩៨.–** អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើតនិងការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្ដិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថា បានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត ។

**មាត្រា ៩៩៩.–** អានុភាពប្រតិសកម្មនៃការទទួលស្គាល់

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ ការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ ។

**មាត្រា ១០០០.–** ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

ឪពុកដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបាន

ឡើយ ។

**មាត្រា ១០០១.-** បណ្ដឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

## កថាភាគទី ៤
## បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

**មាត្រា ១០០២.–** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

១-កូន អាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬ ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាគ្មានហេតុដែលបានសម្រាលក៏ដោយ ។

២-ជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន ។

៣-ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពជាមួយកូនបាន ។

៤-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬ កំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្តាយ នៅក្នុងសៀវភៅ ឬ បើអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអានុភាពនៃការទទួលស្គាល់ បានកើតឡើង ។

៥-ប្រសិនបើកូនជាអនីតិជន ឪពុក ឬ ម្តាយ ដែលមិនមែនជាភាគីម្ខាងទៀតនៃបណ្តឹង ត្រូវធ្វើជាតំណាងឱ្យកូន ។ បើគ្មានឪពុកម្តាយ បើឪពុកម្តាយមិនអាចធ្វើជាតំណាងបាន ឬ បើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពត្រូវបានធ្វើឡើងចំពោះឪពុកម្តាយទាំងសងខាង ជាភាគីម្ខាងទៀតនៃបណ្តឹង តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

**មាត្រា ១០០៣.–** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## កថាភាគទី ៥

## បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

**មាត្រា ១០០៤.–** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន

១-កូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាម្តាយ ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្តាយ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ម្តាយ ប្រសិនបើបានដឹងថាជាម្តាយ នៅក្រោយមរណភាពរបស់ម្តាយ ។

៦-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព ជំនួសជនទាំងនោះបាន ។

**មាត្រា ១០០៥.–** បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្ដាយ

១-ម្ដាយ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបាន ។

២-ម្ដាយ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។

៣-ម្ដាយ ត្រូវដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលខ្លួនបានដឹងថាជាកូន ។

៤-ម្ដាយ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូន នៅក្រោយមរណភាពរបស់កូន ។

៥-ប្រសិនបើម្ដាយជាជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ៣ និង ទី ៤ ខាងលើនេះ បានកន្លងផុត អំឡុងពេលនៃកថាខណ្ឌទី ៣ និង ទី ៤ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៦-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូន ដែលជាភាគីម្ខាងនៃបណ្ដឹងជានីតិជន បើគ្មានការយល់ព្រមពីកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ ម្ដាយមិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានឡើយ ។

៧-ទោះបីជាក្នុងករណីដែលអង្គហេតុនៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ ប្រសិនបើការបញ្ជាក់មាតុភាព ផ្ទុយនឹងផលប្រយោជន៍របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ តុលាការអាចលើកចោលបណ្ដឹងរបស់ម្ដាយបាន ។

**មាត្រា ១០០៦.–** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២
## សុំកូន

### កថាភាគទី ១
### សុំកូនពេញលេញ

**មាត្រា ១០០៧.–** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.–** សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.–** អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

# ឧបសម្ព័ន្ធទី២

# អនុក្រឹត្យ

# ស្តីពី

# អត្រានុកូលដ្ឋាន

១២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ...១០៣...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## អត្រានុកូលដ្ឋាន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសឱ្យប្រើដោយក្រឹត្យ លេខ ៥៦ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

មាត្រា ១៦ ._

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានអោយបានឯកភាពទូទាំងប្រទេស និងណែនាំបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និង ធានាផ្គត់ផ្គង់សៀវភៅ និង សំបុត្រអត្រានុកូលដ្ឋានអោយបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤
## អំពីសំបុត្រកំណើត

មាត្រា ១៧ ._

បើមានទារកកើត ឪពុក ឬ ម្តាយ មានភាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃទារកនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងច្បាស់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើតអោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

មាត្រា ១៨ ._

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្តាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។

មាត្រា ១៩ ._

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់អោយ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និង កំណត់ហេតុស្តីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

**មាត្រា ២០ ._**

ចំពោះទារក ឬ កុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្តីរាយការណ៍ និង នាំទារក ឬ កុមារនោះទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្តល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតអោយ ។

**មាត្រា ២១ ._**

ការសុំទារក ឬ កុមារ ពីជម្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬ កូនពីឳពុក ម្តាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។
កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ២២ ._**

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្តាយ ឬ ឳពុក ។

**មាត្រា ២៣ ._**

ទារកកើត ឳពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឳពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឳពុក ម្តាយនោះថាជាឳពុក ម្តាយរបស់កូននោះ ។ ករណីមានតែឳពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។
ក្រោយពេលឳពុក ឬ ម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឳពុកឬ ម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឳពុក ឬ ម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។
កូនឥតខាន់ស្លាដែលឳពុក ម្តាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឳពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើវេលាលង្ការ និង ពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

មាត្រា ២៤ .-

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់អោយអ្នករាយការណ៍នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

មាត្រា ២៥ .-

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

មាត្រា ២៦ .-

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរម្តាយជាជនបរទេស ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះអាចសុំចុះ សៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញអោយ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មីអោយយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់អោយនោះមកពីប្រើប្រាស់ជាផ្លូវការបាន ។

មាត្រា ២៧ .-

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះ

សៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចហៅចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្ដាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងរួមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥

## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨ ._**

បុរស ស្ត្រី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យអោយបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្ដីពីការអាពាហ៍ពិពាហ៍ និង គ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩ ._**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួននារី ០១ ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់នៃសាមីខ្លួនបុរស ០១ ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ ៖

១-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្ដី ប្រពន្ធ ។

២-នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្ដាយ នៃអនាគត ប្ដី ប្រពន្ធ
បើឪពុក ឬ ម្ដាយស្លាប់ ត្រូវដាក់ថាស្លាប់ ។

៣-រយៈពេលប្ដឹងជំទាស់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នេះ ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍

# ឧបសម្ព័ន្ធទី៣

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

ROYAUME du CAMBODGE

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនីយ សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

**មាត្រា២៣.**_ ដីកាសម្រេចបង្គាប់ឱ្យអនុវត្ត

១-ក្នុងករណីដែលមានបុគ្គលណាធ្វេសប្រហែសមិនអនុវត្តនូវករណីយកិច្ចដែលមានគោលបំណងឱ្យបង់ប្រាក់ ឬ ឱ្យផ្តល់តាវកាលិកនូវទ្រព្យសម្បត្តិផ្សេង ដែលកំណត់ដោយសេចក្តីសម្រេច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២២ (សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍) ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការដែលបានធ្វើការសម្រេចសេចក្តីនេះ អាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន ។

២- ដើម្បីបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកមានករណីយកិច្ចនោះ ។

៣- ប្រសិនបើបុគ្គលដែលត្រូវបានបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានធ្វើតាមការបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការដែលបានបង្គាប់ឱ្យអនុវត្តករណីយកិច្ចនោះ អាចបង្គាប់ឱ្យពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន ។

៤- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ជំពូកទី ៩
## ករណីពិសេសនៃបណ្តឹងអំពីទំនាក់ទំនងឪពុកម្តាយ និង កូន (បុត្តតាព)

**មាត្រា ២៤.**_ ភាគីនៃបណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក ជាអាទិ៍

១- ក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាពមុនកំណើតរបស់កូន ឬ ក្នុងករណីដែលជននោះបានទទួលមរណភាពក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) នៃក្រមរដ្ឋប្បវេណី ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬ ញាតិលោហិតផ្សេងទៀត ក្នុង ៣ (បី) ថ្នាក់របស់ជនដែលត្រូវបានសន្មតថាជាឪពុកអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលជនត្រូវបានសន្មតថាជាឪពុកនោះបានទទួលមរណភាព ។

២- ក្នុងករណីដែលជនដែលបានត្រូវសន្មតថាជាឪពុក បានទទួលមរណភាពក្រោយពេលបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ)ឆ្នាំ គិតពីថ្ងៃដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា

១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៥.**_ ភាគីនៃបណ្តឹងបដិសេធបិតុភាពពីកូន ជាអាទិ៍

១- ក្នុងករណីដែលកូនបានទទួលមរណភាព ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធនូវបិតុភាព មុននឹងក្លាយជានីតិជន ឬ ដោយមិនបានដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី បច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។

២- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព បច្ឆាញាតិផ្ទាល់របស់កូនដែលទទួលមរណភាពនោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៦.**_ ភាគីនៃបណ្តឹងទាមទារឱ្យទទួលស្គាល់ ជាអាទិ៍

១- នៅក្នុងបណ្តឹងទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្តឹង ដោយយកឪពុកមកជាចុងចម្លើយ ។ ក្រោយមរណភាពរបស់ឪពុក ត្រូវយកតំណាងអយ្យការមកជាចុងចម្លើយ ។

២- ប្រសិនបើឪពុកដែលជាចុងចម្លើយ ទទួលមរណភាព នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ ។

៣- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព ទោះបីអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៥ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី បានកន្លងផុតក៏ដោយ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាកនិងការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ២៧.**_ គោលការណ៍នៃវិធានការអន្តរកាល

១- ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យ បណ្តឹងត្រូវបាន

ROYAUME DU CAMBODGE ... LE PALAIS ROYAL



Ksl